# ព្រឹត្តិបត្រ នារីរតនៈ

# NEARY RATTANAK NEWSLETTER

២០១៥. លេខ៥១ ឆ្នាំទី៩




សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ជូនបាច់ផ្កាសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុនសែន

ប្រធានកាកបាទក្រហមកម្ពុជា ក្នុងឱកាសអបអរសាទរ ខួបលើកទី ១០៤ ទិវាអន្តរជាតិនារី

៨ មីនា ឆ្នាំ២០១៥

ចេញផ្សាយពីនាយកដ្ឋានព័ត៌មាន នៃក្រសួងកិច្ចការនារី

Organized by Information Department of Ministry of Women's Affairs

គេហទំព័រ: www.mwa.gov.kh

## គណៈកម្មការត្រួតពិនិត្យ

-លោកជំទាវ **ខេង សំវ៉ាដា** រដ្ឋលេខាធិការ

-លោកជំទាវ **ឡុង សុផល្លី** អនុរដ្ឋលេខាធិការ

-លោកស្រី **យិន សាវ៉ាត់** ប្រធាននាយកដ្ឋាន

## គណៈកម្មការនិពន្ធ

-លោកស្រី **អ៊ុង ខេមរា**

-លោកស្រី **ប៉ែន គន្ធា**

-លោក **ប៉ែន ជា**

-លោកស្រី **តែ សុខខេង**

## រៀបរៀង និងក្រាហ្វិចកុំព្យូទ័រ

-លោកស្រី **ប្រាក់ សោភា**

-លោក **ផុន ពុធបូរី**

-កញ្ញា **ទឹម ពេជ្រកេស្សី**

# មាតិកា


- សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ.......................០១

- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន..ទិវាអន្តរជាតិនារី ..០៣

-គណៈប្រតិភូនារីសម្តែងការគួរសម នៅព្រឹទ្ធសភា រដ្ឋសភា.........១៥

-សកម្មភាពអបអរសាទរទិវាអន្តរជាតិនារី ៨មីនា លើកទី១០៤......១៦

-សម្រង់សុន្ទរកថាសម្តេចក្រឡាហោម ស ខេង..." ការប្តេជ្ញាចិត្ត"..២១

-សម្រង់ខ្លឹមសារសុន្ទរកថាលោកជំទាវ ម៉ែន សំអន...ក្នុងឱកាស..២៥

-ពិធីបើកវេទិកាយុវជនដេញដោល ស្តីពីយេនឌ័រ.........................៣០

-ស្ត្រីទណ្ឌិតមានផ្ទៃពោះ......ត្រូវបានលើកលែងទោស................៣២

-អ្នកគ្រូកម្ពុជាទី១ត្រូវបានជ្រើសតាំងជាឯកអគ្គរដ្ឋទូត.................៣៣

-ម្ចាស់មេដាយមាសចំនួន ១៦...................................................៣៦



**ការិយាល័យនិពន្ធ**
**នាយកដ្ឋានព័ត៌មាន ក្រសួងកិច្ចការនារី ផ្លូវត្រុងមាន់ ភូមិដំណាក់ធំIII សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ**
Editorial Office : Information Department, Ministry of Women's Affairs
Street Trung Meann,Phum DamNakThom III, S.K. Steng MeanChey, Khan MeanChey, Phnom Penh, Cambodia. Tel: 023 880 737

# សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ



សម្តេចព្រះមហាក្សត្រី **នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ទទួលគណៈប្រតិភូស្ត្រីនៅប្រាសាទសិរីមង្គល

គណៈប្រតិភូនារីដឹកនាំដោយលោកជំទាវ វេជ្ជ. **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងមន្ត្រីរាជការនៃស្ថាប័នពាក់ព័ន្ធ អភិបាលរងខេត្តជាស្ត្រី និងប្រធាន អនុប្រធានមន្ទីរកិច្ចការនារី រាជធានីខេត្តសរុបចំនួន១៨០នាក់ បានចូលក្រាបបង្គំគាល់សម្តេចព្រះមហាក្សត្រី **នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ នៅប្រាសាទសិរីមង្គល ដើម្បីទូលថ្វាយនូវរបាយការណ៍អំពីវឌ្ឍនភាពការងាររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងរបាយការណ៍សមិទ្ធផលដែលស្ត្រីកម្ពុជាសំរេចបានរយៈពេល២០ឆ្នាំ ក្រោយសន្និសិទស្ត្រីពិភពលោកឆ្នាំ ១៩៩៥។







លោកជំទាវ ឯកឧត្តម ថតរូបអនុស្សាវរីយ៍ជាមួយសម្តេចព្រះមហាក្សត្រី **នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ



ទិដ្ឋភាពគណៈប្រតិភូនារីក្នុងពិធីក្រាបបង្គំគាល់សម្តេចព្រះមហាក្សត្រី **នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ នៅប្រាសាទសិរីមង្គល

លោកជំទាវរដ្ឋមន្ត្រីបានមានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងកិច្ចការនារីជាសេនាធិការ បានប្តេជ្ញាចិត្តខ្ពស់ក្នុងការអនុវត្តសេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងប៉េកាំង ដោយបានជ្រើសយកបញ្ហាកង្វល់ចំនួន៦ ដាក់ជាវិស័យអាទិភាពនៅក្នុងផែនការយុទ្ធសាស្ត្រនារីរតនៈទី១ ទី២ ទី៣ និងបន្តក្នុងផែនការនារីរតនៈទី៤ ស្របតាមស្ថានភាពរបស់ប្រទេសជាតិ ដែលចំណុចទាំង៦នោះមាន៖ ១.ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ២.ការអប់រំស្ត្រី និងក្មេងស្រី និងការផ្លាស់ប្តូរឥរិយាបថ ៣.សុខភាពស្ត្រី និងក្មេងស្រី រួមទាំងមេរោគអេដស៍ និងអាហារូបត្ថម្ភ ៤.កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី ៥.ស្ត្រីក្នុងការធ្វើសេចក្តីសម្រេច និងការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល និង៦.យេនឌ័រ និងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ។ ***សារ៉ាត់***

# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា ចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងឱកាសអបអរសាទរ ខួបលើកទី ១០៤ ទិវាអន្តរជាតិនារី ៨ មីនា នៅវិមានសន្តិភាព ឆ្នាំ២០១៥




## សុន្ទរកថា

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ក្នុងពិធីអបអរសាទរខួបទី ១០៤ ទិវាអន្តរជាតិនារី

## ៨ មីនា ឆ្នាំ ២០១៥ វិមានសន្តិភាព

## ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០១៥

*-ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី និងក្មួយៗនិស្សិត ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ*

*-អង្គពិធីទាំងមូលជាទីមេត្រី!*

ថ្ងៃនេះ ខ្ញុំ និងភរិយាពិតជាមានសេចក្តីរីករាយដោយបានមកចូលរួមអបអរសាទរ**ខួបទី ១០៤ នៃទិវាអន្តរជាតិ នារី ៨ មីនា ឆ្នាំ ២០១៥** ដែលត្រូវបានប្រារព្ធឡើងយ៉ាងឱឡារិកនាពេលនេះ។

ជាបឋម ខ្ញុំសូមសម្តែងនូវការគាំទ្រចំពោះការរៀបចំសកម្មភាពសំខាន់ៗ នៅក្នុងការប្រារព្ធពិធីអបអរសាទរទិវានេះក្រោមប្រធានបទ " **ដំណើរឆ្ពោះទៅមុខ៖ ស្ត្រីកម្ពុជាក្រោយសន្និសីទស្ត្រីពិភពលោក ឆ្នាំ**

**១៩៩៥** " ដែលទិវានេះបានរំលឹកពីការខិតខំប្រឹងប្រែងតស៊ូរបស់នារី ដើម្បីសិទ្ធិសេរីភាព ប្រជាធិបតេយ្យ ព្រមទាំងជាឱកាសពិនិត្យមើលពីសមិទ្ធផលនានា ដែលកើតមានក្នុងរយៈពេល ២០ ឆ្នាំកន្លងមក ដើម្បីបន្តគិតគូរយកចិត្តទុកដាក់ខ្ពស់ដល់ភាពរីកចម្រើនរបស់ស្ត្រីតទៅអនាគតទៀត។ ជារួម កិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លា និងឆន្ទៈដ៏មោះមុតរបស់គ្រប់ក្រសួងស្ថាប័នរដ្ឋ រួមទាំងស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ តុលាការ និងវិស័យឯកជន អង្គការសង្គមស៊ីវិល ព្រមទាំងការចូលរួមពីប្រជាពលរដ្ឋទូទាំងព្រះរាជាណាចក្រកម្ពុជានាពេលកន្លងមកបង្កើតបានសមិទ្ធផលដ៏ច្រើនគួរឱ្យកត់សម្គាល់ ក្នុងការងារលើកកម្ពស់សិទ្ធិស្ត្រីដែលជាមោទនភាពមួយរបស់ជាតិយើង។ ភាពរីកចម្រើន និងជោគជ័យគួរឱ្យកត់សម្គាល់នេះ ក៏បានឆ្លើយតបទៅនឹងផែនការសកម្មភាពទីក្រុងប៉េកាំងឆ្នាំ១៩៩៥ ដែលមានមូលដ្ឋានលើការលើកកម្ពស់សិទ្ធិស្ត្រីក្នុងវិស័យសេដ្ឋកិច្ចសង្គម នយោបាយ រួមទាំងការបង្កើនសមត្ថភាព សុខុមាលភាព និងសុវត្ថិភាពដល់ស្ត្រី។

ការរំលឹកខួបទី២០ នៃសេចក្តីប្រកាសផែនការសកម្មភាពនាទីក្រុងប៉េកាំងឆ្នាំ ១៩៩៥ មិនគ្រាន់តែធ្វើការវាយតម្លៃលើសមិទ្ធផលដែលសម្រេចបានប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ធ្វើការពិនិត្យមើលឡើងវិញ និងស្វែងរកដំណោះស្រាយលើបញ្ហាប្រឈមនានា ដើម្បីបង្កើននូវល័ក្ខខ័ណ្ឌអំណោយផលឱ្យមានការទទួលស្គាល់សមភាពរវាងស្ត្រី និងបុរសក្នុងគ្រប់ទិដ្ឋភាពនៃវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច ព្រមទាំងសិទ្ធិ និងសេរីភាពរបស់ស្ត្រីក្នុងការចូលរួមចំណែកដោយស្មើភាព និងក្នុងភាពជាដៃគូមិនអាចខ្វះបានជាមួយបុរសក្នុងការរួមចំណែកអភិវឌ្ឍប្រទេសជាតិ។

ឈរលើមូលដ្ឋាន នៃកិច្ចខិតខំប្រឹងប្រែងកន្លងមកនេះកម្ពុជាទទួលបាននូវសន្ទស្សន៍កើនឡើយលើការអភិវឌ្ឍធនធានមនុស្សក្នុងឆ្នាំ២០១៣ ដោយទទួលចំណាត់ថ្នាក់លេខ១៣៨ ក្នុងចំណោម១៨៧ប្រទេស។ ជាមួយនេះសន្ទស្សន៍សមភាពយេនឌ័រថ្មីបំផុតក្នុងឆ្នាំ២០១៣ បង្ហាញថា កម្ពុជាជាប់ចំណាត់ថ្នាក់ទី១៣៦ ក្នុងចំណោម ១៨៣ ប្រទេសលើវិស័យសុខភាពបន្តពូជ ការអប់រំ ការធ្វើសេចក្តីសម្រេច និងការចូលរួមរបស់ស្ត្រីក្នុងទីផ្សារពលកម្ម។ ប៉ុន្តែទោះបីជាកម្ពុជាបានធ្វើឱ្យមានភាពជឿនលឿនទាក់ទងនឹងសមភាពយេនឌ័រ រួមទាំងការពង្រឹងភាពអង់អាចដល់ស្ត្រីក៏ដោយ ក៏យើងនៅមានបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយដែលក្នុងនោះរួមមាន (**១**). វិសមភាពយេនឌ័រដែលនៅមាននៅឡើយក្នុងវិស័យអប់រំជាពិសេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា ដែលអាចប៉ះពាល់ដល់ការលានុវត្តភាពផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីមានជាអាទិ៍ ការទទួលបាននូវចំណេះដឹង ជំនាញ និងបច្ចេកវិទ្យាថ្មី (**២**).បញ្ហាសុខភាពស្ត្រី អាហារូបត្ថម្ភ អត្រាស្លាប់របស់ម្តាយនៅតែជាបញ្ហាប្រឈមដ៏សំខាន់នៅឡើយ បើប្រៀបធៀបទៅនឹងប្រទេសដទៃនៅក្នុងតំបន់ (**៣**). ការដោះស្រាយបញ្ហាអំពើហិង្សាលើស្ត្រី និងកុមារីទៅតាមនីតិវិធីតុលាការ

និងផ្លូវច្បាប់នៅពុំទាន់បានរលូន និងទាន់ពេលវេលានៅឡើយ (៤). ស្ត្រីចូលរួមក្នុងការធ្វើសេចក្តីសម្រេច និងនៅក្នុងវិស័យសេដ្ឋកិច្ចនៅមានកម្រិតនៅឡើយ ដោយសារបទដ្ឋានសង្គម និងវប្បធម៌នៅមានឥទ្ធិពលដល់ក្មេងស្រី ដោយមិនចាំបាច់តម្រូវឱ្យរៀនសូត្រខ្ពស់ត្រូវនៅធ្វើការងារផ្ទះ ដែលជាហេតុធ្វើឱ្យស្ត្រីភាគច្រើនធ្វើការងារមានប្រាក់កម្រៃទាប និងងាយទទួលរងគ្រោះ ហើយមិនបានចូលរួមសកម្មខ្លាំងក្លាក្នុងវិស័យសាធារណៈ និងនយោបាយជាដើម។

*-ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី និងក្មួយៗនិស្សិត!*

ឆ្លើយតបទៅនឹងបញ្ហាទាំងអស់នេះ ក៏ដូចជាការអនុវត្តផែនការសកម្មភាពនៃសន្និសីទស្ត្រីពិភព-លោកនាទីក្រុងប៉េកាំងឆ្នាំ១៩៩៥ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១, ទី២, ទី៣ ដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាពផ្តោះទៅកសាងស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ហើយជាលទ្ធផលបានធ្វើឱ្យកម្ពុជាមានកំណើនសេដ្ឋកិច្ចយ៉ាងលឿន ហើយស្ត្រីមានឱកាសការងារកាន់តែច្រើនសម្រាប់ពង្រឹងភាពជាម្ចាស់ និងជួយបង្កើនសេដ្ឋកិច្ចគ្រួសាររបស់ពួកគេ។ ជាក់ស្តែងកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ជាមធ្យម ៧,៧% ក្នុងមួយឆ្នាំ ក្នុងអំឡុង ២ទសវត្សរ៍កន្លងមកហើយ ជីវភាព និងសុខុមាលភាពរបស់ប្រជាជនកាន់តែត្រូវបានលើកកម្ពស់គួរឱ្យកត់សម្គាល់ ក្នុងនោះអត្រានៃភាពក្រីក្រប្រមាណជាង ២% ក្នុងមួយឆ្នាំ ត្រូវបានកាត់បន្ថយ និងបានពង្រីកឱកាសកាន់តែច្រើនសម្រាប់ស្ត្រីចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចកម្លាំងពលកម្មនៅគ្រប់កម្រិត។ ក្នុងមូលដ្ឋាននេះ កម្ពុជាមិនត្រឹមតែសម្រេចបានជោគជ័យគួរជាទីមោទនៈក្នុងការអនុវត្តការងារចំគោលដៅភាគច្រើន នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបានអង្គការសហប្រជាជាតិជ្រើសរើសជាប្រទេសគំរូសម្រាប់ការអនុវត្តសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទៀតផង។

ដូចអង្គពិធីបានជ្រាបរួចមកហើយលទ្ធផល និងសមិទ្ធផលទាំងអស់នេះកើតមានឡើងដោយសារកត្តាស្ថិរភាពនយោបាយពេញលេញ ដែលធ្វើឱ្យកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការអនុវត្តការកែទម្រង់លើគ្រប់វិស័យ ព្រមទាំងការអភិវឌ្ឍធនធានមនុស្សផងដែរ ហើយក្នុងនោះការលើកម្ពស់ស្ថានភាពស្ត្រីក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់ ដោយបានបង្កើតឱ្យមានស្ថាប័នកិច្ចការនារី និងដំឡើងទៅជាក្រសួងកិច្ចការនារីនៅឆ្នាំ១៩៩៦ ដែលបានដើរតួនាទីជាកាតាលិករ និងស្វែងរកមតិគាំទ្រ ក្នុងការលើកទឹកចិត្តស្ថាប័នសាធារណៈ សង្គមស៊ីវិល និងវិស័យឯកជន ដើម្បីបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីរបស់ស្ថាប័នទាំងនោះ។ ដោយផ្អែកលើបទពិសោធន៍នេះ ក្រសួងកិច្ចការនារីបានបំពេញតួនាទីក្នុងអាណត្តិរបស់ខ្លួន ដោយបានរៀបចំផែនការយុទ្ធសាស្ត្រជាតិជាបន្តបន្ទាប់ដែលហៅថា នារីរតនៈទី១ ដល់ទី៣

ដោយអនុវត្តបានដោយជោគជ័យក្នុងការលើកកម្ពស់ស្ថានភាពស្ត្រីនៅកម្ពុជា ជាពិសេស ការចូលរួមជាមួយចលនាស្ត្រីនៅលើពិភពលោក និងកិច្ចសហការនៅក្នុងតំបន់។

ឆ្លៀតឱកាសនេះ ខ្ញុំសូមគូសរំលេចខ្លះៗអំពីដំណើរវិវឌ្ឍនៃការងារលើកកម្ពស់សិទ្ធិស្ត្រី ការលើកតម្លៃស្ត្រី និងការងារយេនឌ័រនៅកម្ពុជាជូនអង្គមិទ្ធិញបានជ្រួតជ្រាបទាំងអស់គ្នា។ ជារួម ក្នុងខណៈដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅមុខ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវច្បាប់ គោលនយោបាយ និងយន្តការជាតិជាច្រើនទៀតដើម្បីបន្តលើកកម្ពស់ស្ថានភាពសិទ្ធិ ឋានៈ និងតួនាទីរបស់ស្ត្រីកម្ពុជាឱ្យកាន់តែមានភាពល្អប្រសើរឡើងឱ្យប្រកបដោយសមធម៌ គាំទ្រឱ្យសម្រេចបាននូវសមភាពដ៏ពិតប្រាកដរវាង បុរស និងស្ត្រីដោយទទួលស្គាល់ថា "**ស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ**"។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ខ្ពស់ក្នុងការជំរុញសមធម៌យេនឌ័រ និងដំណើរឆ្ពោះទៅរកសមភាពយេនឌ័រពិតប្រាកដឱ្យដល់កម្រិតខ្ពស់ដោយចាត់ទុកថា ស្ត្រីជាកម្លាំងដែលមិនអាចខ្វះបានឡើយ ក្នុងការរួមចំណែកធ្វើឱ្យសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលដែលនឹងត្រូវប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។ ជាក់ស្តែងយន្តការ ដែលប្រកបដោយការទទួលខុសត្រូវមាននិរន្តរភាព និងកិច្ចសហការរួមគ្នា ក្នុងរយៈកាលពីរទសវត្សរ៍កន្លងមកនេះ បានធ្វើឱ្យសមភាពយេនឌ័រនៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ពោលគឺ ស្ត្រីបានទទួលនូវអត្ថប្រយោជន៍ពីកម្មវិធីកាត់បន្ថយភាពក្រីក្រពិតប្រាកដ មានកំណើនសេដ្ឋកិច្ចគ្រួសារកាន់តែរឹងមាំ និងបានចូលរួមកាន់តែសកម្មនៅក្នុងវិស័យសង្គម និងសេដ្ឋកិច្ច។

ទន្ទឹមនោះ ចាប់ពីឆ្នាំ១៩៩៩ មក ការកាត់បន្ថយវិសមភាពយេនឌ័រ និងការដោះស្រាយតម្រូវការរបស់ស្ត្រី និងក្មេងស្រីនៅកម្ពុជាមានភាពកាន់តែប្រសើរឡើង ដែលជាទូទៅស្ត្រីកម្ពុជាបានចូលរួមយ៉ាងសកម្ម ក្នុងការអភិវឌ្ឍន៍សង្គមលើគ្រប់វិស័យ ជាពិសេសវិស័យសេដ្ឋកិច្ច នយោបាយ និងការធ្វើសេចក្តីសម្រេច។ លើសពីនេះទៀត រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ជំរុញការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដើម្បីពង្រីកលទ្ធភាពរបស់ស្ត្រី និងកុមារទាំងនៅតំបន់ទីក្រុង និងនៅជនបទឱ្យទទួលបានកាលានុវត្តភាពនៅគ្រប់វិស័យ។ នៅថ្នាក់ជាតិ រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារបញ្ជ្រាបយេនឌ័រនៅក្នុងក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលសម្របសម្រួលដោយក្រសួងកិច្ចការនារី។ នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ក៏មានយន្តការពិសេសដែលមានការចូលរួមពីស្ត្រីសម្រាប់ជួយដោះស្រាយនូវបញ្ហាទាំងឡាយរបស់ស្ត្រី។

ដោយឡែក ការបង្កើតភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៅកម្ពុជាទទួលបានលទ្ធផលល្អប្រសើរដោយស្ត្រីកម្ពុជាចូលរួមក្នុងទីផ្សារពលកម្មប្រមាណ ៧៩,២% បើប្រៀបធៀបទៅនឹងបុរសប្រមាណ ៨៦,៧%។

ទន្ទឹមនេះ ការស្រាវជ្រាវជាអន្តរជាតិមួយដោយអ្នកវិភាគសេដ្ឋកិច្ចលើសទ្ទស្សន៍ឱកាសសេដ្ឋកិច្ច សម្រាប់ស្ត្រី ឆ្នាំ២០១២ បានអះអាងថា កម្ពុជាគឺជាប្រទេសទី៣ក្នុងពិភពលោក ដែលមានគោលនយោបាយការងារឆ្លើយតបនឹងយេនឌ័រ និងការលើកកម្ពស់សមភាពការងារ រួមទាំងការផ្តល់ឱកាសសម្រាប់ស្ត្រី និងសិទ្ធិក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ ជាការពិតនៅក្នុងកម្មវិធីនយោបាយរបស់ខ្លួន រាជរដ្ឋាភិបាលទទួលស្គាល់ថា ស្ត្រីបានដើរតួនាទីសំខាន់ក្នុងការចូលរួមអភិវឌ្ឍសង្គម សេដ្ឋកិច្ច ជាពិសេសនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅផ្លូវការ។ ក្នុងនោះដែររាជរដ្ឋភិបាល ក៏បានចាត់ទុកការងារមេផ្ទះដែលមិនមានកម្រៃរបស់ស្ត្រីជាផ្នែកមួយនៃសេដ្ឋកិច្ចជាតិ មានសារៈសំខាន់ក្នុងការរួមចំណែកក្នុងការលើកម្ពស់ជីវភាពគ្រួសារ ដូចបានបញ្ជាក់ក្នុងមាត្រា ៣៦ នៃរដ្ឋធម្មនុញ្ញ " **ការងារមេផ្ទះមានតម្លៃស្មើគ្នា និងកម្រៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ** "។

ច្បាប់ និងគោលនយោបាយសំខាន់ៗ និងផែនការសកម្មភាពជាតិសម្រាប់ដោះស្រាយអំពើហិង្សាទាក់ទង់នឹងយេនឌ័រត្រូវបានបង្កើតឡើង និងអនុវត្ត ដើម្បីកាត់បន្ថយភាពងាយរងគ្រោះដោយអំពើហិង្សាលើស្ត្រី និងកុមារនៅក្នុងសង្គម។ គោលនយោបាយជាតិកំពុងបញ្ចូលនូវវិធានការពិសេសៗជាច្រើន ដើម្បីធ្វើឱ្យសម្រេចនូវសិទ្ធិរបស់ក្រុមស្ត្រីងាយរងគ្រោះ ដោយសារបញ្ហាសេដ្ឋកិច្ច សង្គម សុខភាពអប់រំ និងទទួលរងអំពើហិង្សា ដូចដែលបានឆ្លុះបញ្ចាំងក្នុងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ និងនារីរតនៈទី៤។ ទន្លឹមនឹងនេះរាជរដ្ឋាភិបាលបានបន្តយកចិត្តទុកដាក់ចំពោះក្រុមជនងាយរងគ្រោះ ពិសេសស្ត្រី និងកុមារដោយបានពង្រឹងជាប្រចាំនូវស្មារតីសាមគ្គីប្រជាជាតិជាធ្លុងមួយ និងការអភិវឌ្ឍមូលធនមនុស្សដោយគ្មានការរើសអើង តាមរយៈការអនុម័ត និងការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធជនពិការ គោលនយោបាយ ស្តីពី ការអប់រំកុមារពិការជាដើម។ ជាមួយគ្នានេះ រាជរដ្ឋបាលភិបាលក៏បានយកចិត្តទុកដាក់ក្នុងការរៀបចំគោលនយោបាយសម្រាប់មនុស្សចាស់ជរាគ្មានទីពឹង និងជនជាតិភាគតិចផងដែរ។ ក្នុងនោះយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្របានរួមចំណែកលើកកម្ពស់ជីវភាពស្ត្រីតាមរយៈការកែលំអហេដ្ឋារចនាសម្ព័ន្ធ ដូចជាការស្ថាបនាផ្លូវដែលជួយឱ្យស្ត្រីស្វែងរកសេវាសុខភាព ការបង្កើតមុខរបរ ការដឹកជញ្ជូនបានកាន់តែប្រសើរ។ កម្ពុជាក៏បានចាត់ទុកជាអាទិភាពលើការលើកកម្ពស់ប្រព័ន្ធសុខភាព ការថែទាំអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ជាដើម។ ដោយឡែកការវិនិយោគក្នុងវិស័យកសិកម្ម និងឧស្សាហកម្មបានធ្វើឱ្យស្ត្រីទទួលបានចំណូលកាន់តែច្រើនសម្រាប់ការលើកកម្ពស់ជីវភាពរស់នៅរបស់ខ្លួន។ គោលនយោបាយជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងងាយរងគ្រោះត្រូវបានអនុម័តក្នុងឆ្នាំ២០១១ និងអង្គភាពគាំពារសង្គមកំពុងដាក់ឱ្យដំណើរការដើម្បីគាំទ្រស្ត្រីក្រីក្រ។ មាតា និងកុមារក្រីក្រ និងក្រុមជនងាយរងគ្រោះនឹងទទួលផលប្រយោជន៍ពីបណ្តាញសុវត្ថិភាព សង្គម និងកម្មវិធីកាត់បន្ថយភាពក្រីក្រ តាមរយៈការអភិវឌ្ឍធនធានមនុស្ស ការធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ

សុខភាពមាតា និងទារក ការលើកកម្ពស់ការអប់រំ និងលុបបំបាត់ពលកម្មកុមារជាពិសេសទម្រង់ពលកម្មធ្ងន់ធ្ងរ។

ដោយឡែកចំពោះយុវជន រាជរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា សំដៅអភិវឌ្ឍទាំងចំណេះដឹង ចំណេះធ្វើ សុខភាព កាយសម្បទា និងសីលធម៌ ឱ្យក្លាយទៅជាមូលធនមនុស្សប្រកបដោយសក្តានុពល និងផ្តល់ឱកាសឱ្យពួកគេចូលរួមចំណែកក្នុងការធ្វើសេចក្តីសម្រេចក៏ដូចជាក្នុងការអភិវឌ្ឍគ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូល។ ជាក់ស្តែងយុវជនបានបំពេញតួនាទីយ៉ាងសំខាន់ក្នុងកិច្ចការងារសង្គម តាមរយៈចលនាកាយឬទ្ធិ យុវជនកាកបាទក្រហម យុវជនស្ម័គ្រចិត្តក្នុងការងារអនុវត្តគោលនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី ព្រមទាំងចលនាយុវជនក្នុងការលើកតម្កើងវប្បធម៌ប្រពៃណី អត្តសញ្ញាណជាតិ ក្នុងកិច្ចការពារបរិស្ថានសំដៅ ប្រែក្លាយយុវជនឱ្យក្លាយទៅជាកម្លាំងចលករដ៏មានសារៈសំខាន់សម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យ។

ចំណែកវិស័យនយោបាយ និងតួនាទីធ្វើសេចក្តីសម្រេចរាជរដ្ឋាភិបាលក៏បានបង្កើតចំនួនស្ត្រីក្នុងតួនាទី និងតំណែងសំខាន់នៅគ្រប់ក្រសួង-ស្ថាប័ន និងគ្រប់កម្រិត ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចបានរៀបរាប់ក្នុងសុន្ទរកថាស្វាគមន៍របស់លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី។

លទ្ធផល និងសមិទ្ធផលទាំងឡាយដែលបានរៀបរាប់ខាងលើគឺជាកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាជាបន្តបន្ទាប់ក្នុងការលើកកម្ពស់ស្ថានភាពស្ត្រីនៅកម្ពុជាលើគ្រប់វិស័យ។ថ្មីៗនេះទៀតសោត យើងក៏បានគិតគូរបន្ថែមទៀតដល់ការលើកលែងទោសចំពោះស្ត្រីមានគិតនិងមានកូនដែលជាប់ពន្ធនាគារ ដែលជាកាយវិការដ៏វិសេសថ្លៃថ្លាមួយធ្វើឱ្យស្ត្រីជាអ្នកទោសមួយចំនួនទទួលបាននូវតម្លៃ និងក្តីសង្ឃឹមក្នុងជីវិតឡើងវិញ។ នេះជាការគិតគូរសំខាន់មួយចំពោះស្ត្រីការរួមចំណែកលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី ដើម្បីធ្វើឱ្យសង្គមជាតិឆ្ពោះទៅរកស្ថានភាពមួយប្រកបដោយសីលធម៌ថ្លៃថ្នូរ សុភមង្គល និងសុខដុមរមនា។

***-ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី និងក្មួយៗនិស្សិត!***

សមិទ្ធផល២០ឆ្នាំក្រោយសន្និសីទស្ត្រីទីក្រុងប៉េកាំងឆ្នាំ១៩៩៥បានផ្តល់នូវបទពិសោធន៍ជាវិជ្ជមាននិងអវិជ្ជមានយ៉ាងច្រើន។ ហេតុនេះដំណើរឆ្ពោះទៅរកបរិការណ៍នៃការអភិវឌ្ឍក្រោយឆ្នាំ ២០១៥ អ្នកធ្វើគោលនយោបាយត្រូវរៀបចំខ្លួនចាប់យកឱកាស និងដោះស្រាយបញ្ហាប្រឈមនានាដែលនៅមាន ហើយក្រសួងស្ថាប័នត្រូវរួមគ្នាពន្លឿនការលើកកម្ពស់សមភាពយេនឌ័រ តម្លៃស្ត្រី សិទ្ធិស្ត្រី ទប់ស្កាត់អំពើហិង្សា ការរំលោភសេពសន្ថវៈ អំពើជួញដូរស្ត្រី ហើយចាំបាច់បញ្ចូលសមភាពយេនឌ័រជាគោលដៅមួយ ដោយឡែកនៅក្នុងគោលដៅអភិវឌ្ឍប្រកបដោយចិរភាពក្រោយឆ្នាំ២០១៥ នៅក្នុងបរិការណ៍នៃប្រទេសនីមួយៗ។

ជារួមយើងបានដឹងហើយថា បញ្ហាអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ អំពើជួញដូរ និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ បញ្ហាគ្រឿងញៀនជាដើមនៅតែជាកង្វល់ចំពោះមុខរបស់យើងនៅឡើយ។ បញ្ហាទាំងអស់នេះទាមទារឱ្យយើងទាំងអស់គ្នាត្រូវបន្តយកចិត្តទុកដាក់ខិតខំប្រឹងប្រែងពុះពារជម្នះ និងដោះស្រាយដោយស្វាហាប់ និងកាន់តែមានប្រសិទ្ធភាពថែមទៀតដើម្បីធ្វើឱ្យប្រជាជនយើងពិសេសស្ត្រីកម្ពុជាទទួលបានកាលានុវត្តភាពពេញលេញសម្រាប់រួមចំណែកកាន់តែសកម្មផុលផុសក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិរបស់យើង។ ក្នុងស្មារតីនេះខ្ញុំសូមផ្តល់ការណែនាំមួយចំនួនបន្ថែមទៀតទៅលើកិច្ចខិតខំប្រឹងប្រែងដែលមានដោយផ្តោតលើការងារជាអាទិភាពមួយចំនួនដូចខាងក្រោម៖

*__ទី១.__បន្តពង្រឹងយន្តការជាតិដែលមានស្រាប់ ដើម្បីឱ្យស្ថាប័នទាំងនោះអាចដើរតួនាទីដឹកនាំ និងអនុវត្តគោលនយោបាយស្តីពីយេនឌ័រនៅក្នុងវិស័យរបស់ខ្លួនផងដែរ។ ក្នុងនេះត្រូវបន្តធ្វើការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ផ្អែកទៅលើឯកសារនៃសេចក្តីសង្កេតសន្និដ្ឋានឆ្នាំ២០១៣របស់គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទ នៃអង្គការសហប្រជាជាតិ។*

*__ទី២.__បន្តកសាងភាពជាដៃគូរឹងមាំជាមួយសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធទាំងឡាយ ជាពិសេសស្ត្រី និងបុរសវ័យក្មេង ដែលធ្វើការតស៊ូមតិដើម្បីសមភាពយេនឌ័រ។ ជាការពិតការលើកកម្ពស់សមភាពយេនឌ័រ ការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច និងសង្គម មិនត្រឹមតែត្រូវបន្តអនុវត្តជាសកម្មភាពអាទិភាពនៅកម្រិតជាតិប៉ុណ្ណោះទេ ប៉ុន្តែចាំបាច់តម្រូវឱ្យមានជាគោលដៅមួយដាច់ដោយឡែកនៅក្នុងរបៀបវារៈអភិវឌ្ឍអន្តរជាតិក្រោយឆ្នាំ២០១៥ ក៏ដូចជាបញ្ជ្រាបទៅក្នុងគោលបំណងទាំងអស់ក្នុងរបៀបវារៈនៃបរិការណ៍អាស៊ានទៀតផង។*

*__ទី៣.__ ក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវបញ្ចូលវិធានការ ដែលបានឯកភាពគ្នាចែងនៅក្នុងផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ ទៅក្នុងផែនការ និងយុទ្ធសាស្ត្ររបស់ខ្លួន។ ជាមួយនេះត្រូវផ្តោតការយកចិត្តទុកដាក់ដល់ការពិនិត្យតាមដាន និងការអនុវត្តការងារនេះ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្នុងនោះត្រូវជំរុញបង្កើនសមាមាត្រនៃការចូលរួមរបស់ស្ត្រីក្នុងស្ថាប័នសាធារណៈ និងវិស័យឯកជន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធ្វើឱ្យស្ត្រីចូលរួមយ៉ាងសកម្មក្នុងការធ្វើសេចក្តីសម្រេចការងារអភិបាលកិច្ច និងសកម្មភាពសេដ្ឋកិច្ចនៅគ្រប់កម្រិត។*

*__ទី៤.__អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍គួររៀបចំផែនការសកម្មភាពរបស់ខ្លួនស្របទៅតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការ ៥ឆ្នាំនារីរតនៈទី៤ ជាពិសេសអភិក្រមទូទាំងកម្មវិធី ដែលដាក់ចេញដោយរាជរដ្ឋាភិបាលដើម្បីទទួលបានលទ្ធផលរួមគ្នា។ សូមដៃគូអភិវឌ្ឍន៍ទាំងឡាយបន្តជួយគាំទ្រក្រសួងកិច្ចការនារី និងក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តផែនការនារីរតនៈទី៤ និងផែនការ*

សកម្មភាពជាតិនានា។

**ទី៥.** វិស័យឯកជនគួរមានគំនិតផ្តួចផ្តើមនានា ក្នុងគោលដៅរួមចំណែកជំរុញ និងលើកកម្ពស់សមភាពយេនឌ័រព្រមទាំងសហការជាមួយស្ថាប័នពាក់ព័ន្ធចាត់វិធានការបង្កើនលក្ខខ័ណ្ឌការងារសមរម្យសម្រាប់ស្ត្រី។

**ទី៦.** ក្មួយៗយុវជន យុវនារីទាំងអស់ត្រូវខិតខំរៀនសូត្រ និងប្រកាន់ខ្ជាប់នូវសីលធម៌ ដើម្បីក្លាយជាមូលធនបញ្ញាដ៏មានសក្តានុពលក្នុងការរួមចំណែកអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិ ដោយចៀសវាងការប្រើប្រាស់ចំណេះដឹង និងបច្ចេកវិទ្យាខុសទិសដៅ ដែលអាចបង្កឱ្យមានអំពើហិង្សា ភាពចលាចល ដែលនាំមកនូវអស្ថិរភាពសង្គម ឬធ្វើឱ្យបាត់បង់សេចក្តីថ្លៃថ្នូររបស់ស្ត្រី។ ក្មួយៗត្រូវប្រែក្លាយចំណេះដឹង ជំនាញ និងបទពិសោធន៍ទាំងឡាយ ឱ្យទៅជាឧត្តមប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូល ជាពិសេសការលើកកម្ពស់សមភាពយេនឌ័រ និងតម្លៃរបស់ស្ត្រី។ ទន្ទឹមនេះ សមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ត្រូវចូលរួមឱ្យបានពេញលេញក្នុងការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព ជាពិសេសចូលរួមទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ និងត្រូវផ្តល់ឱកាសដល់ស្ត្រី និងកុមារី និងសមាជិកសហគមន៍ដែលជាស្ត្រីក្នុងការបង្កើនទំនុកចិត្តលើខ្លួនឯង និងកសាងសមត្ថភាព។

**ទី៧.** មាតាបិតា និងអ្នកអាណាព្យាបាលត្រូវជួយអប់រំបុត្រធីតា តាមគោលការណ៍នៃព្រហ្មវិហារធម៌ រួមទាំង សីលធម៌ សុជីវធម៌ និងផ្តល់ឱកាសឱ្យកូនប្រុស កូនស្រីរៀនបានខ្ពង់ខ្ពស់ អាចរហូតដល់កម្រិតឧត្តមសិក្សា ដើម្បីធ្វើឱ្យគ្រួសារកាន់តែមានភាពចម្រើនរុងរឿង និងសង្គមកាន់តែមានសុខដុមរមនា ពិសេសកាត់បន្ថយវិសមភាពយេនឌ័រនៅក្នុងវិស័យអប់រំ។

**ទី៨.** ត្រូវរួមគ្នាបន្តលើកកម្ពស់សិទ្ធិ ស្ថានភាព និងផ្តល់ការយកចិត្តទុកដាក់កាន់តែខ្ពស់ដល់ស្ត្រី និងក្មេងស្រីងាយរងគ្រោះ ដូចជា ស្ត្រីពិការ ស្ត្រីវ័យចំណាស់និងជនជាតិភាគតិច។ល។ ដើម្បីឱ្យពួកគាត់បានទទួលចំណេះដឹង ជំនាញវិជ្ជាជីវៈសម្រាប់ប្រកបមុខរបរបង្កើនប្រាក់ចំណូលក្នុងគ្រួសារ និងបានទទួលនូវសេវាទៅតាមតម្រូវការពិសេសរបស់ពួកគាត់ និងទៅតាមលទ្ធភាពដែលមាន។

ក្នុងស្មារតីដូចបានលើឡើងមកនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធវិស័យឯកជន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងបងប្អូនជនរួមជាតិទាំងអស់នឹងរួមគ្នាបន្តទៀតក្នុងគោលដៅលើកកម្ពស់សិទ្ធិ តម្លៃ សេចក្តីថ្លៃថ្នូររបស់ស្ត្រី និងយេនឌ័រនៅម្ពុជា។

*-ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី និងក្មួយៗ និស្សិត!*

ឆ្លៀតក្នុងឱកាសនេះខ្ញុំសូមកោតសរសើរដល់ក្រសួងកិច្ចការនារី ក្រសួង-ស្ថាប័នជាតិវិស័យឯកជន សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងអង្គការជាតិ-អន្តរជាតិទាំងអស់ ដែលបានរួមចំណែកគាំទ្រការលើកម្ពស់

ស្ថានភាពជីវភាព សិទ្ធិ ឋានៈ តួនាទីរបស់ស្ត្រី ជាពិសេសបានសហការ និងផ្តល់ធនធានសម្រាប់ ប្រារព្ធទិវាអន្តរជាតិនារី ៨ នារី ឆ្នាំ ២០១៥ នេះ ហើយសូមបន្តការគាំទ្រ និងប្រែក្លាយខ្លឹមសារនៃប្រធានបទ **" ដំណើរឆ្ពោះទៅមុខ៖ ស្ត្រីកម្ពុជាក្រោយសន្និសីទស្ត្រីពិភពលោកឆ្នាំ១៩៩៥ "** ឱ្យទៅជាសកម្មភាពជាក់ស្តែង ដើម្បីកម្ពុជាសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចិរភាព។

ជាទីបញ្ចប់ឆ្លៀតក្នុងឱកាសនៃ **ខួបទី ១០៤ នៃទិវាអន្តរជាតិ នារី ៨ មីនា ឆ្នាំ ២០១៥** នេះ ក្នុងនាមរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាទូទាំងប្រទេសទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ និងភរិយាសូមថ្វាយព្រះពរជ័យសិរីមង្គលបវរមហាប្រសើរថ្វាយសម្តេចព្រះមហាក្សត្រី **នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល សូមថ្វាយព្រះពរព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមគុណបុណ្យព្រះរតនៈត្រ័យ ទេវតារក្សាព្រះមហាស្វេតច្ឆត្រតេជៈបារមីនៃអតីតព្រះមហាក្សត្រខ្មែរគ្រប់ព្រះអង្គ និងវត្ថុស័ក្តិសិទ្ធិដែលរក្សាព្រះរាជាណាចក្រកម្ពុជា សូមតាមជួយប្រោះព្រំថែរក្សាព្រះអង្គ និងសូមបានប្រកបដោយព្រះរាជសុខភាពបរិបូណ៌ ព្រះពលំមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីព្រះអង្គគង់ជាម្លប់ដ៏ត្រជាក់ដល់ប្រជានុរាស្ត្រគ្រប់រូបទូទាំងព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ក្មួយៗនិស្សិត និងភ្ញៀវជាតិអន្តរជាតិទាំងអស់ សូមមានសុខភាពបរិបូណ៌ទទួលបានជោគជ័យក្នុងគ្រប់ភារកិច្ច និងសូមប្រកបដោយពុទ្ធពរទាំងបួនប្រការ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ *សូមអរគុណ!*



**លោកជំទាវវេជ្ជ. អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ជូនបាច់ផ្កាសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុនសែន**

# សម្រង់ខ្លឹមសារសំខាន់ៗនៃសុន្ទរកថា លោកជំទាវវេជ្ជ. អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ក្នុងឱកាសប្រារព្ធពិធីអបអរសាទរ ខួបទី១០៤ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០១៥ ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៥ នៅវិមានសន្តិភាព រាជធានីភ្នំពេញ

---សន្និសីទស្ត្រីពិភពលោកលើកទី៤ ឆ្នាំ ១៩៩៥ បានដាក់ចេញសេចក្តីប្រកាស និងផែនការសកម្មភាពទីក្រុងប៉េកាំង ដែលជាការប្តេជ្ញាចិត្តខ្ពស់គ្របដណ្តប់លើកង្វល់ចម្បងជាអាទិភាព១២ ចំណុចមានជាអាទ៍ ភាពក្រីក្រ ការអប់រំ សុខភាព អំពើ ហិង្សាលើស្ត្រី ស្ត្រីក្នុងបរិបថនៃជម្លោះអាវុធ ស្ត្រីក្នុងរចនាសម្ព័ន្ធនយោបាយ ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច តួនាទីស្ត្រីក្នុងការធ្វើសេចក្តី សម្រេចយន្តការលើកកម្ពស់ស្ថានភាពស្ត្រី សិទ្ធិស្ត្រីលើប្រព័ន្ធផ្សព្វផ្សាយបរិស្ថាន និងបញ្ហាកុមារី ។

និយាយជារួម ស្ថានភាពរបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជាមានការរីកចម្រើនក្នុងរយៈពេល ២០ឆ្នាំ កន្លងមកនេះ។ ស្ត្រីបានទទួលនូវអត្ថ-ប្រយោជន៍ពីសុខសន្តិភាព ស្ថិរភាពនយោបាយ កំណើនសេដ្ឋកិច្ចជាតិដ៏រឹងមាំ ព្រមទាំងការកាត់បន្ថយភាពក្រីក្រនិងការកែលំអសេវាសាធារណៈ។ ការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ចមានការកើនឡើង ហើយមានកម្រិតខ្ពស់បំផុតនៅក្នុងតំបន់។ នៅក្នុងវិស័យអប់រំ សមភាពយេនឌ័រត្រូវបានធ្វើឱ្យសម្រេចនៅកម្រិតបឋមសិក្សា រីឯការសិក្សានៅមធ្យមសិក្សាបឋម ភូមិ និងទុតិយភូមិស្ទើរសម្រេចបានទាំងស្រុង។ ប៉ុន្តែគម្លាតរវាងក្មេងប្រុសនិងក្មេងស្រីនៅកម្រិតឧត្តមសិក្សានៅមាននៅឡើយ។ បន្ថែមលើចំណុចនេះ ដោយមានកិច្ចខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡាសហការជាមួយនឹងដៃគូពាក់ព័ន្ធ ជាពិសេសតាមរយៈយុទ្ធនាការអក្ខរកម្មជាតិ កម្រិតអក្ខរកម្មរបស់ក្រុមមនុស្សវ័យក្មេង មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ជាក់ស្តែងគ្មាន គម្លាតយេនឌ័រក្នុងអក្ខរកម្មសម្រាប់ប្រជាជនមានអាយុតិចជាង២៥ឆ្នាំ។ អត្រាមរណភាពមាតាត្រូវបានកាត់បន្ថយ៦១% នៅចន្លោះឆ្នាំ២០០០ដល់ឆ្នាំ២០១៤(១៧០/១០០.០០០កំណើតរស់ក្នុងឆ្នាំ២០១៤[1]) ដោយចំនួនស្ត្រីកាន់តែច្រើនទទួលបាននូវសេវាផ្នែកថែទាំសុខភាពសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ រួមទាំងសេវាពន្យារកំណើត និងសេវារំលូតកូនប្រកបដោយសុវត្ថិភាព។ ច្បាប់ និងគោលនយោបាយដែលឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រត្រូវបានបង្កើត និងកំពុងអនុវត្តយ៉ាងសកម្មដើម្បីទប់ស្កាត់និងបង្ក្រាបអំពើហិង្សាបែបនេះ។ សេវាច្បាប់ សេវាសុខាភិបាល និងសង្គមកិច្ចជូនស្ត្រីរងគ្រោះដោយអំពើហិង្សា មានភាពប្រសើរឡើង ហើយទិន្នន័យអំពីស្ត្រីទទួលរងអំពើហិង្សាត្រូវបាននិងកំពុងប្រមូល ដោយប្រើប្រាស់នូវវិធីសាស្ត្រអង្កេត ដែលទទួលស្គាល់ជាអន្តរជាតិក្នុងគោលបំណងវាស់វែងឱ្យបានច្បាស់លាស់លើប្រសិទ្ធភាព នៃការងារជួយជនរងគ្រោះ។

ការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យនយោបាយ

និងសាធារណៈក៏មានការកើនឡើងផងដែរ៖ ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០១៣ ចំនួនស្ត្រីជាសមាជិកសភាមានការកើនឡើងពី ៥.៨% មក២០.៣% ស្ត្រីជាឧបនាយករដ្ឋមន្ត្រីពី០ មក ១រូបស្ត្រីជារដ្ឋមន្ត្រី និងប្រធានស្ថាប័នពី០ មក ៣រូប (អាជ្ញាធរសវនកម្មជាតិ) ស្ត្រីជារដ្ឋលេខាធិការពី០ មក ៣៨រូប និងស្ត្រីជាអនុរដ្ឋលេខាធិការពី២ មក ៤៨រូប។ ចំពោះមន្ត្រីរាជការស៊ីវិលពីឆ្នាំ២០០៧ ដល់២០១៣ បានកើនឡើងពី៣២% ដល់៣៧%។ ក្នុងឆ្នាំ២០១៤ ប្រព័ន្ធយុត្តិធម៌ និងតុលាការ ស្ត្រីជាព្រះរាជអាជ្ញាមាន១រូប ហើយ១៤រូបជាព្រះរាជអាជ្ញារង ស្ត្រីជាចៅក្រមមាន៣៦រូប ស្ត្រីជាក្រឡាបញ្ជីមាន១៦៨រូប ហើយស្ត្រីជាមេធាវីមាន១៥៨រូប ។

នៅថ្នាក់ក្រោមជាតិ ស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងឆ្នាំ២០០២ ដល់ឆ្នាំ២០១២ បានកើនឡើងពី៩.៤% ដល់១៧.៨% ស្ត្រីជាប់ឆ្នោតក្នុងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៤ បានកើនឡើងពី១០% ដល់១៣.២% ហើយស្ត្រីជាអភិបាលរងរាជធានីខេត្តមាន២៥រូប ស្ត្រីជាអភិបាលក្រុង ស្រុក ខណ្ឌមាន ៣រូប[2] ស្ត្រីជាអភិបាលរងក្រុង ស្រុក ខណ្ឌមាន១៩៣រូប។

ដើម្បីបង្កើនយន្តការជាតិបញ្ជ្រាបយេនឌ័ររាជរដ្ឋាភិបាលបានបង្កើតក្រុមការងារបញ្ជ្រាបយេនឌ័រនៅគ្រប់ក្រសួង ក្រុមនេះសម្របសម្រួលដោយក្រសួងកិច្ចការនារី។ នៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ក៏មានយន្តការពិសេសផងដែរ តាមរយៈគណៈកម្មាធិការពិគ្រោះយោបល់ និងទទួលបន្ទុកកិច្ចការនារី និងកុមារ សម្រាប់ជួយដោះស្រាយនូវបញ្ហាទាំងឡាយរបស់ស្ត្រី និងកុមារ។

សមិទ្ធផលទាំងនេះ ឆ្លុះបញ្ចាំងឱ្យឃើញពីការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការលើកកម្ពស់សមភាពយេនឌ័រ រួមចំណែកពង្រឹងអភិបាលកិច្ចល្អ និងលទ្ធិប្រជាធិបតេយ្យ។ ប្រសិទ្ធភាពនៃការងារនេះត្រូវបានធ្វើឱ្យសម្រេចតាមរយៈភាពជាដៃគូជាមួយនឹងស្ថាប័ននីតិបញ្ញត្តិ ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងប្រជាជនខ្លួនឯង។

ទោះបីជាប្រទេសកម្ពុជា បានធ្វើឱ្យមានភាពជឿនលឿនទាក់ទងនឹងសមភាពយេនឌ័រ រួមទាំងការពង្រឹងភាពអង់អាចរបស់ស្ត្រីក៏ដោយ ក៏នៅមានបញ្ហាប្រឈមនៅឡើយ។

បច្ចុប្បន្ន ស្ត្រីអាយុលើសពី១៥ឆ្នាំចំនួន ២៥.៦%[3] ជាអនក្ខរជន ហើយនៅមានវិសមភាពយេនឌ័រគួរឱ្យកត់សម្គាល់នៅឡើយ នៅកម្រិតមធ្យមសិក្សាទុតិយភូមិតាមតំបន់ជនបទ និងឧត្តមសិក្សា នេះធ្វើឱ្យប៉ះពាល់ដល់កាលានុវត្តភាពផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី ដែលជាឧបសគ្គក្នុងការទទួលបាននូវចំណេះដឹង និងវិជ្ជាជីវៈថ្មីៗ។ ម៉្យាងទៀតថ្វីត្បិតតែស្ត្រីចំនួន៨០.៩%[4] ចូលរួមក្នុងកម្លាំងពលកម្មសេដ្ឋកិច្ចជាតិ ក៏ប៉ុន្តែ៨២%ចូលរួមក្នុង

សេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ចំពោះការងារមានប្រាក់កម្រៃខ្ពស់ ស្ត្រីមានតែ២៧%[5] ប៉ុណ្ណោះ បើធៀបជាមួយបុរសមានដល់ទៅ៧៣%។ រីឯការងារកសិកម្មវិញស្ត្រីមានតែ១៣.២%[6] ប៉ុណ្ណោះ ជាម្ចាស់លើដីកសិកម្ម ដែលជាឧបសគ្គក្នុងការជួយគ្រួសាររបស់គេឱ្យរួចផុតពីភាពក្រីក្រ។ លើផ្នែកសុខភាពស្ត្រី អត្រាមរណភាពមាតា ពិតមែនតែមានការថយចុះគួរឱ្យកត់សម្គាល់ ក៏ប៉ុន្តែនៅតែមានកម្រិតខ្ពស់នៅឡើយ បើប្រៀបធៀបនៅក្នុងតំបន់ ដោយមកពីកត្តាកង្វះការយល់ដឹងអំពីសុខភាព អនាម័យ អាហារូបត្ថម្ភ ភាពទន់ខ្សោយផ្នែកសេដ្ឋកិច្ច និងការអប់រំទាបរបស់ស្ត្រី រួមទាំងការផ្តល់និងទទួលយកសេវានៅមានកម្រិត។ ចំពោះការជួញដូរស្ត្រីនិងកុមារ និងអំពើហិង្សាលើស្ត្រីនិងកុមារ នៅមានបញ្ហាប្រឈមបណ្តាលមកពីផ្នត់គំនិត និងឥរិយាបថសង្គម ភាពក្រីក្រ ការខ្វះការយល់ដឹងអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការសេពសុរា និងប្រើប្រាស់គ្រឿងញៀន ការផ្សព្វផ្សាយព័ត៌មានពុំមានសីលធម៌ សុជីវធម៌ តាមរយៈប្រព័ន្ធអេឡិចត្រូនិក បណ្តាលឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពប្រជាជន និងប្រពៃណីដ៏ល្អផូរផង់របស់ប្រទេសជាតិ។

រីឯស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច ថ្វីត្បិតតែមានការកើនឡើងនូវចំនួនស្ត្រីជាអ្នកដឹកនាំនៅគ្រប់លំដាប់ថ្នាក់ក៏ដោយ ក៏នៅតែមានបញ្ហាប្រឈមដោយសារសមត្ថភាពរបស់ស្ត្រីខ្លួនឯងនៅមានកម្រិត ខ្វះការគាំទ្រពីគ្រួសារ សហគមន៍ គណបក្សនយោបាយ និងពីអង្គភាពការងារផងដែរ ។

ពិតមែនតែក្រសួងកិច្ចការនារី រួមជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ បានខិតខំអនុវត្តសកម្មភាពដោះស្រាយបញ្ហាដែលស្ត្រីជួបប្រទះក្នុងសង្គមជាតិ និងសង្គមគ្រួសារយ៉ាងសកម្មក៏ដោយ ក៏ប៉ុន្តែការងារដ៏ធំធេងនេះ មិនអាចធ្វើទៅបាន កន្លងមកបើមិនមានការគាំទ្រយ៉ាងពេញទំហឹងពីរាជរដ្ឋាភិបាល ស្ថាប័ននីតិបញ្ញត្តិ តុលាការ ស្ថាប័នរដ្ឋ និងឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងសង្គមស៊ីវិល និង ប្រជាជន។

ក្នុងនាមក្រសួងកិច្ចការនារី និងគណៈកម្មការរៀបចំ នាងខ្ញុំសូមសម្តែងនូវអំណរគុណ និងដឹងគុណប្រកបដោយក្តីកតញ្ញូដ៏ជ្រាលជ្រៅជូនចំពោះសម្តេចតេជោនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់ ចំពោះសណ្តានចិត្តប្រកបដោយព្រហ្មវិហារធម៌ និងឆន្ទៈដ៏មោះមុតក្នុងការលើកកម្ពស់ស្ថានភាពស្ត្រី។ ជាសក្ខីភាព ការគិតគូរលើកលែងទោសដល់ស្ត្រីមានគភ៌ និងមានកូនដែលជាប់ពន្ធនាគារ ក៏ដូចជាការតែងតាំងស្ត្រីជាថ្នាក់ដឹកនាំនៅគ្រប់ក្រសួង ស្ថាប័ន ដែលនេះជាកាយវិការដ៏វិសេសថ្លៃថ្លាធ្វើឱ្យស្ត្រីកម្ពុជាទទួលបាននូវតម្លៃនិងក្តីសង្ឃឹមក្នុងជីវិត។ នាងខ្ញុំសូមអនុញ្ញាតថ្លែងអំណរគុណផងដែរ ជូនចំពោះសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប្រធានកាកបាទក្រហមកម្ពុជា និងជាប្រធានកិត្តិយសគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ដែលបានគាំទ្រជាស្មារតី និងសម្ភារៈដល់រាល់សកម្មភាពនៃគណៈកម្មាធិការជាតិ ដែលរួមចំណែកធ្វើឱ្យសង្គមគ្រួសារ និងសង្គមជាតិឆ្ពោះទៅរកស្ថានភាពមួយប្រកបដោយសីលធម៌ថ្លៃថ្នូរ សុភមង្គល និងសុខដុមរមនា៕




គណៈប្រតិភូនារីកម្ពុជាចំនួន ១៤៥នាក់ ដឹកនាំដោយលោកជំទាវវេជ្ជ. **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានចូលជួបសំដែងការគួរសម និងរាយការណ៍ពីវឌ្ឍនភាពនៃស្ថានភាពស្ត្រីកម្ពុជា ព្រមទាំងថតរូបអនុស្សាវរីយ៍ជាមួយឯកឧត្តម **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសអបអរសាទរខួបលើកទី ១០៥ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០១៥ នៅវិមានចំការមន ។







គណៈប្រតិភូនារីកម្ពុជាចំនួន ១៥៥នាក់ ដឹកនាំដោយលោកជំទាវ **ឃឹម ចំរើន** រដ្ឋលេខាធិការនៃក្រសួងកិច្ចការនារី បានចូលជួបសំដែងការគួរសម និងរាយការណ៍ពីវឌ្ឍនភាពនៃស្ថានភាពស្ត្រីកម្ពុជា ជូនឯកឧត្តម **ខួន ញឹល** អនុប្រធានទី២ រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសអបអរសាទរខួបលើកទី ១០៥ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០១៥ នៅវិមានរដ្ឋសភា។




លោកជំទាវវេជ្ជ.**អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារីជាគណៈអធិបតីក្នុងវេទិកាយុវវ័យជជែកពិភាក្សាតាមទូរទស្សន៍ ស្តីពី សមភាពយេនឌ័រ ដើម្បីឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន ក្នុងចំណោមស្រទាប់យុវវ័យលើបញ្ហាយេនឌ័រ និងបង្កើនការយកចិត្តទុកដាក់លើបញ្ហាយេនឌ័រពីសំណាក់ក្រុមអ្នកតាក់តែងគោលនយោបាយ ក្រុមយុវវ័យ និងមហាជនទូទៅ។ ការជជែកពិភាក្សានេះមានលក្ខណៈប្រកួតប្រជែងដោយភ្ជាប់នឹងសារអប់រំ ធ្វើឡើងជា២ជុំ និងមាននិស្សិតមកពីបណ្តាគ្រឹះស្ថានឧត្តមសិក្សាចំនួន០៨ចូលរួម។ ជាលទ្ធផលជ័យលាភីលេខមួយក្នុងកម្មវិធីយុវវ័យជជែកពិភាក្សាតាមទូរទស្សន៍នេះ បានទៅក្រុមនិស្សិតដែលមកពីសាកលវិទ្យាល័យប៊ែលធីអន្តរជាតិ។




**គណៈអធិបតីថតរូបអនុស្សាវរីយ៍ ជាមួយនិស្សិត ដែលទទួលបានជ័យលាភី**




លោកជំទាវ **ឃឹម ចំរើន** រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី ជាគណៈអធិបតីក្នុងវេទិកាតុមូលអបអរសាទរខួបលើកទី ១០៤ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០១៥ ក្រោមប្រធានបទ " ដំណើរឆ្ពោះទៅមុខ៖ **ស្ត្រីកម្ពុជាក្រោយសន្និសីទស្ត្រីពិភពលោកឆ្នាំ ១៩៩៥** " នៅទូរទស្សន៍ជាតិកម្ពុជា បានលើកឡើងពីវឌ្ឍនភាពរបស់ស្ត្រីក្នុងរយៈពេល ២០ឆ្នាំកន្លងមក បញ្ហាប្រឈម យន្តការ និងវិធានការអនុវត្តបន្តដោយផ្តោតលើវិស័យជាអាទិភាពរួមមាន៖ វិស័យអប់រំ វិស័យសុខាភិបាល វិស័យការពារផ្លូវច្បាប់ និងស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច។ លោកជំទាវបានមានប្រសាសន៍ថា រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើជនពិការ ដោយបង្កើតឱ្យមានគោលនយោបាយដើម្បីការពារជនពិការ ក្នុងនោះបានដាក់បញ្ចូលឱ្យមានជនពិការ





បម្រើការងារក្នុងវិស័យមុខងារសាធារណៈយ៉ាងតិច២% នៅគ្រប់ក្រសួង-ស្ថាប័ន៕

## អនុគណៈកម្មការផ្សព្វផ្សាយតាមសាលារៀន

បានរៀបចំវេទិកាអបអរសាទរខួបលើកទី១០៨ ទិវាអន្តរជាតិនារី៨មីនា ជាមួយសិស្សានុសិស្ស ជារបៀប សំណួរចម្លើយដើម្បីបង្កើនចំណេះដឹងពាក់ព័ន្ធនឹងប្រធានបទ " ដំណើរឆ្ពោះទៅមុខៈស្ត្រីកម្ពុជាក្រោយសន្និសីទស្ត្រីពិភពលោកឆ្នាំ១៩៩៥ " នៅតាមសាកលវិទ្យាល័យ និងវិទ្យាល័យចំនួន៦៖ សាកលវិទ្យាល័យ ភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យអាស៊ីអឺរ៉ុប វិទ្យាល័យជាស៊ីមចំរើនរដ្ឋ វិទ្យាល័យព្រែកឯង វិទ្យាល័យសម្តេចហ៊ុនសែនភ្នំពេញថ្មី និងវិទ្យាល័យហ៊ុនសែនជម្ពូវ័ន្ត អ្នកចូលរួមសរុបចំនួន១.៨៩៩នាក់ (ស្ត្រី៨០៦នាក់)។




លោកជំទាវ **សាន្ត អារុណ** រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី ជាគណៈអធិបតី នៅវិទ្យាល័យព្រែកឯង




លោកជំទាវ **អ៊ឹម ស៊ីថៃ** រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី ជាគណៈអធិបតី នៅវិទ្យាល័យសែនសុខភ្នំពេញថ្មី







លោកជំទាវ **ស៊ីវណ្ណា បុទុម** រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី ជាគណៈអធិបតីក្នុងឱកាសអបអរសាទរខួបលើកទី ១០៤ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០១៥ បានចុះផ្សព្វផ្សាយដល់កម្មករកម្មការនីរោងចក្រចំនួន៦ ដែលមានអ្នកចូលរួមសរុបចំនួន ១.៨៦៩នាក់ (ស្រី ១.៧៧០នាក់)។




**ទិវា៨មីនា ឆ្នាំ២០១៥ ក្រោមអធិបតីភាព ឯកឧត្តម ថង សាវុន**



**អ្នកចូលរួមក្នុងអង្គពិធី**

ឯកឧត្តម **ថង សាវុន** អភិបាលនៃគណៈអភិបាលខេត្តរតនគិរី ជាគណៈអធិបតីក្នុងទិវាអន្តរជាតិនារី៨មីនា ខួបលើកទី១០៤ ឆ្នាំ២០១៥ នៅមន្ទីរវប្បធម៌ រៀបចំដោយមន្ទីរកិច្ចការនារី ខេត្តរតនគិរី ។




**លោកជំទាវរដ្ឋមន្ត្រីថតរូបអនុស្សាវរីយ៍ជាមួយគណៈប្រតិភូមហាអនុតំបន់មេគង្គ**

កាលពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥ នៅសណ្ឋាគារសុខាភ្នំពេញ និងរេស៊ីដង់ ក្រសួងកិច្ចការនារីបានរៀបចំកិច្ចប្រជុំអន្តរជាតិ ( ***ស្តីពី ការសម្របសម្រួលគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីប្រឆាំងការជួញដូរ នៅមហាអនុតំបន់មេគង្គ***) ចំនួន ២លើក ក្រោមប្រធានបទ " **ការប្តេជ្ញាចិត្តថ្នាក់តំបន់ដើម្បីបញ្ឈប់អំពើជួញដូរមនុស្ស តាមការរួបរួមគ្នា និងការបង្កើតគំនិតថ្មី** " ដោយមានការអញ្ជើញចូលរួមរបស់គណៈប្រតិភូនៃមហាអនុតំបន់មេគង្គ មានកម្ពុជា ចិន ឡាវ ភូមា ថៃ និងវៀតណាម ចំនួនពីរវគ្គគឺ៖

-ថ្ងៃទី២៨-២៩ ខែមេសា ឆ្នាំ២០១៥ កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ប្រឆាំងអំពើជួញដូរមនុស្សមហាអនុតំបន់ទន្លេមេគង្គលើកទី១០ ក្រោមអធិបតីភាពលោកជំទាវវេជ្ជ. **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាអនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

-ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥ កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៃដំណើរការ " **ការប្តេជ្ញាចិត្តថ្នាក់តំបន់ដើម្បីបញ្ឈប់អំពើជួញដូរមនុស្ស តាមការរួបរួមគ្នា និងការបង្កើតគំនិតថ្មី** " លើកទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។




**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ជាអធិបតីក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី ៤**

## សម្រង់សុន្ទរកថា
## សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រោមប្រធានបទ " ការប្តេជ្ញាចិត្តថ្នាក់តំបន់ដើម្បីបញ្ឈប់អំពើជួញដូរមនុស្ស តាមការរួបរួមគ្នា និងការបង្កើតគំនិតថ្មី "

----កិច្ចប្រជុំនេះពិតជាមានសារៈសំខាន់ណាស់ ក្នុងការចែករំលែកនូវព័ត៌មាន គោលគំនិតជាមូលដ្ឋាន និងទិសដៅជាយុទ្ធសាស្ត្រ សម្រាប់ការការពារសុវត្ថិភាពរបស់ប្រជាជនក្នុងតំបន់ដែលកំពុងតែមានតម្រូវការខ្ពស់ក្នុងការស្វែងរកអាជីពសម្រាប់ការរស់នៅកាន់តែប្រសើរឡើង ទាំងនៅក្នុង និងក្រៅប្រទេស ដែលចាំបាច់ត្រូវមានការការពារពីគ្រប់ប្រទេសពាក់ព័ន្ធ។ នៅទីនេះយើងបានបង្ហាញយ៉ាងច្បាស់ពីឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្តជាថ្មីរបស់រដ្ឋាភិបាលនៃប្រទេសទាំង ៦ នៅក្នុងមហាអនុតំបន់មេគង្គដោយបានទទួលស្គាល់ថា អំពើជួញដូរមនុស្ស គឺជារូបភាពនៃទាសករសម័យទំនើបក្នុងសតវត្សរ៍ទី២១នេះ ព្រោះវាបានរំលោភបំពានលើសិទ្ធិជាមូលដ្ឋានរបស់មនុស្សយ៉ាងធ្ងន់ធ្ងរ ហើយផ្តល់នូវទុក្ខវេទនា ដល់ជនរងគ្រោះ ក្រុមគ្រួសារ និងដាក់បន្ទុកដល់សង្គម និងរដ្ឋាភិបាលនៃប្រទេសសាមីដោយមិនអាចជៀសវាងបាន ហើយចាំបាច់ត្រូវបង្កើនកិច្ចសហការដើម្បីដោះស្រាយបញ្ហានេះឱ្យបាន។

*រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តយ៉ាងមោះមុត ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស*

*តាំងពីអំឡុងទសវត្សរ៍ឆ្នាំ៩០ មកម្លេះ ដោយបានចុះហត្ថលេខា និងផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ ដែលពាក់ព័ន្ធនឹងការប្រឆាំង អំពើជួញដូរ និងអំពើហិង្សាលើស្ត្រី ក្នុងឆ្នាំ ១៩៩២ បានអនុម័តច្បាប់ដំបូងស្តីពីការបង្ក្រាបអំពើលក់ដូរ និងការចាប់ពង្រត់មនុស្ស ក្នុងឆ្នាំ១៩៩៦ និងបានរៀបចំច្បាប់ជាថ្មី ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឱ្យស្របតាមការប្រែប្រួលនៃបទល្មើសដែលត្រូវបានអនុម័តនៅឆ្នាំ២០០៨ និងបន្តអនុវត្តដល់បច្ចុប្បន្ន។ ព្រមពេលជាមួយគ្នានោះ រាជរដ្ឋាភិបាលកម្ពុជាក៏បានចូលរួម ជាមួយប្រទេសនានានៃមហាអនុតំបន់មេគង្គក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ស្តីពីគំនិតផ្តួចផ្តើមក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ខមមីត) ក្នុងឆ្នាំ២០០៤ និងបានបង្កើតក្រុមការងារខមមីតកម្ពុជាក្នុងឆ្នាំ ២០០៥ ក៏ដូចជាបានចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំក្រុមមន្ត្រីជាន់ខ្ពស់អាស៊ាន ស្តីពីការប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន (SOMTC)។ បច្ចុប្បន្ននេះ យើងមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ.) មានក្រសួង ស្ថាប័នចំនួន ២២ជាសមាជិក ដឹកនាំដោយឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ គណៈកម្មាធិការជាតិនេះ មានរចនាសម្ព័ន្ធដល់ថ្នាក់ក្រោមជាតិ ដែលគ្របដណ្តប់រហូតដល់ឃុំ សង្កាត់ ព្រមទាំងបើកទូលាយ ឱ្យអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិចូលរួមយ៉ាងសកម្មដើម្បីអនុវត្តយុទ្ធសាស្ត្រទាំង៤ គឺ៖ ការបង្ការទប់ស្កាត់ ការការពារជនរងគ្រោះ ការអនុវត្តច្បាប់ ក្នុងនោះមានការបង្ក្រាប និងការផ្តន្ទាទោស និងការពង្រឹងកិច្ចសហការរវាងដៃគូពាក់ព័ន្ធទាំងក្នុង និងក្រៅប្រទេស តាមរយៈក្រុមការងារ សហប្រតិបត្តិការអន្តរជាតិ ដែលមានក្រុមការងារខមមីត និង SOMTC ជាអ្នកទទួលអនុវត្ត។*

* * *អំពើជួញដូរមនុស្ស និងការរំលោភបំពានកេងប្រវ័ញ្ចលើមនុស្ស នឹងអាចលុបបំបាត់បាន បើយើងប្តេជ្ញាចិត្តរួមគ្នាដើម្បីបំបាត់។ ចំណុចសំខាន់គឺ ប្រទេសដែលមានពលករនិងប្រទេសប្រើប្រាស់កម្លាំងពលកម្ម ត្រូវឯកភាពគ្នាក្នុងការធានាភាពស្របច្បាប់របស់ពលករ ទទួលយកតែពលករស្របច្បាប់ ដោយគោរពលក្ខខណ្ឌការងារ និងសិទ្ធិពលករជាមូលដ្ឋាន។ អ្នកជ្រើសរើសពលករដែលបោកប្រាស់ពលករ ត្រូវផ្តន្ទាទោស និងលុបបំបាត់។ អាជ្ញាធរ និងសមត្ថកិច្ចចាត់វិធានការបង្ក្រាបឱ្យបានទាន់ពេលនូវមេខ្យល់ និងជនខិលខូចដែលយកពលករជាអាជីវកម្ម កេងប្រវ័ញ្ច នឹងប្រព្រឹត្តបទល្មើស ត្រូវទទួលបានការផ្តន្ទាទោសពីតុលាការ។ និយោជក និងពលករ ចេះយល់អធ្យាស្រ័យគ្នា និងចេះចែករំលែកសុខទុក្ខ និងផលប្រយោជន៍រវាងគ្នា ដោយសមស្រប មិនកេងប្រវ័ញ្ច និងរំលោភសិទ្ធិគ្នា មិនអាត្មានិយម មិនគិតតែផលប្រយោជន៍ផ្ទាល់ខ្លួន និងយកចិត្តទុកដាក់ចំពោះការខាតបង់ និងទុក្ខលំបាករបស់អ្នកដទៃ។

ក្នុងតួនាទីជារដ្ឋាភិបាលនៃប្រទេសនីមួយៗ យើងមានភារកិច្ចទទួលខុសត្រូវលើបញ្ហានេះ




**ពិធីចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួមរាជធានីភ្នំពេញ**

ដោយប្រឈមនឹងការលំបាកច្រើន ដោយហេតុថា អំពើជួញដូរមនុស្សជាឧក្រិដ្ឋកម្មឆ្លងដែន ដែលមាន ឬមិនមានអង្គការចាត់តាំង ឬជាប្រព័ន្ធទាក់ទងគ្នា ទាំងតាមរូបភាពស្របច្បាប់ ទាំងមិនស្របច្បាប់ ដូច្នេះមិនអាចស្ថាប័នណាមួយ ឬប្រទេសណាមួយអាចលុបបំបាត់តែម្នាក់ឯងដោយជោគជ័យឡើយ បើមិនមានកិច្ចសហការរវាងអង្គភាព ក្រសួងស្ថាប័ន និងប្រទេសពាក់ព័ន្ធប្រកបដោយឆន្ទៈ ការទទួលខុសត្រូវ និងការប្តេជ្ញាចិត្តខ្ពស់ទេនោះ។ ការធ្វេសប្រហែស គឺជាឱកាសសម្រាប់បទល្មើស។

*ទន្ទឹមនឹងកិច្ចសហការយ៉ាងជិតស្និតរវាងប្រទេសទាំង៦ នៅក្នុងតំបន់តាមរយៈដំណើរការខមមីត យើងក៏ត្រូវការពង្រីកវិសាលភាពនៃកិច្ចសហការ ជាមួយវេទិកាថ្នាក់តំបន់ផ្សេងៗទៀត ដូចជាវេទិកាអាស៊ាន និងដំណើរការទីក្រុងបាលីជាដើម។ ជាមួយនឹងក្តីសង្ឃឹមរបស់សមាជិកអាស៊ាន ក្នុងការអនុម័តអនុសញ្ញាអាស៊ាន ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលនឹងប្រព្រឹត្តទៅនៅចុងឆ្នាំ២០១៥ រួមជាមួយនឹងការរៀបចំផែនការសកម្មភាពថ្នាក់តំបន់ផងដែរនោះ កិច្ចប្រជុំនេះគឺជាឱកាសដ៏មានតម្លៃ ដែលយើងត្រូវតែរួមគ្នាបង្កើននូវកិច្ចសម្របសម្រួល និងកិច្ចអន្តរាគមន៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងតំបន់។ សូមឆ្លៀតយកឱកាសនេះដើម្បីចូលរួមជាអនុសាសន៍មួយចំនួនដូចខាងក្រោម៖*

***១. ដើម្បីឱ្យការអនុវត្តន៍សកម្មភាពមានភាពរលូនជាមួយគ្នា និងទទួលបានប្រសិទ្ធិភាពខ្ពស់ ប្រទេសសមាជិកទាំងអស់គប្បីបង្កើនការយល់ដឹងដូចគ្នា អំពីនិយមន័យ និងរូបភាពនៃការជួញដូរមនុស្ស ដោយ***

មានចែងក្នុងច្បាប់ និងគោលនយោបាយរបស់ប្រទេសនីមួយៗ។

២. ពង្រឹងកិច្ចសហការល្អរវាងប្រទេសពាក់ព័ន្ធនៅក្នុង និងក្រៅតំបន់ ដើម្បីបង្ក្រាបបទល្មើសច្បាប់ និងផ្តន្ទាទោសជនល្មើស ជួយជនរងគ្រោះឱ្យបានទាន់ហេតុការណ៍ និងកាត់បន្ថយនិទណ្ឌភាពដើម្បីភាពយុត្តិធម៌នៅក្នុងសង្គម។

៣. ផ្តល់សេវាកម្មប្រកបដោយគុណភាព ជូនជនរងគ្រោះទាំងផ្នែកប្រឹក្សាយោបល់ ផ្នែកសុខភាពក៏ជាសេវាផ្លូវច្បាប់ឆ្លើយតមទៅនឹងសេចក្តីត្រូវការជាក់ស្តែងរបស់ជនរងគ្រោះ ដែលអាចខុសគ្នារវាងបុរស ស្ត្រី យុវវ័យ និងកុមារ។

៤. បង្កើត ឬបន្តពង្រឹងប្រព័ន្ធប្រមូលទិន្នន័យ និងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃការងារជួញដូរមនុស្ស ដើម្បីកសាងបាននូវសូចនាករ និងសន្ទស្សន៍វាស់វែងភាពប្រែប្រួលនៃបទល្មើស សម្រាប់ការដាក់វិធានការឆ្លើយតប។

៥. ពង្រឹងការអនុវត្តគោលនយោបាយ អនុស្សរណៈ និងផែនការដែលបានព្រមព្រៀងគ្នា ជាទ្វេភាគី និងពហុភាគីឱ្យទទួលបានលទ្ធផលជាក់ស្តែងប្រកបដោយការទទួលខុសត្រូវខ្ពស់។

៦. បន្តតាមដានជាប្រចាំ នូវសកម្មភាព និងប្រសិទ្ធភាពនៃការអនុវត្ត ដោយចែករំលែកលទ្ធផលនៅរៀងរាល់កិច្ចប្រជុំប្រចាំឆ្នាំ។ ក្នុងករណីចាំបាច់ គប្បីផ្តួចផ្តើមឱ្យមានការជួបប្រជុំដោយឡែក ដើម្បីពិភាក្សា និងផ្លាស់ប្តូរបទពិសោធន៍ភាពប្រឈម និងរិះរកយុទ្ធសាស្ត្រ និងដំណោះស្រាយថ្មីៗ ឆ្លើយតបទៅនឹងស្ថានភាព។

៧. ជម្រុញ និងពន្លឿនកិច្ចពិភាក្សាបង្កើត ឬកែសម្រួល និងចុះហត្ថលេខាលើអនុស្សរណៈទ្វេភាគី រវាងប្រទេសពាក់ព័ន្ធឱ្យបានឆាប់ ដើម្បីបង្ការទប់ស្កាត់ភាពរងគ្រោះរបស់ប្រជាជនដោយមិនឱ្យបន្តធ្វើចំណាកស្រុក ដោយប្រថុយប្រថាន ដែលអាចផ្តល់ឱកាសឱ្យជនល្មើសធ្វើសកម្មភាពជួញដូរមនុស្ស និងកេងប្រវ័ញ្ចបន្តទៀត ៕ សារ៉ាត់



ពិធីបើកកិច្ចប្រជុំSOMទី១០ នៅរាជធានីភ្នំពេញ



លោកជំទាវថ្នាក់ដឹកនាំក្រសួងកិច្ចការនារី និងលោកជំទាវថ្នាក់ដឹកនាំអន្តរក្រសួង ថតរូបអនុស្សាវរីយ៍ជាមួយ
លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី

## សម្រង់ខ្លឹមសារសុន្ទរកថា
## លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច
## ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៤
## និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០១៥ របស់ក្រសួងកិច្ចការនារី
## ថ្ងៃទី១ ដល់ ទី២ ខែមេសា ឆ្នាំ២០១៥ នៅសណ្ឋាគារភ្នំពេញ

----រាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានធ្វើឱ្យកម្ពុជារីកចម្រើនលើគ្រប់វិស័យ ទាំងសេដ្ឋកិច្ច សង្គម-កិច្ច នយោបាយការទូត និងមានកិត្យានុភាពលើសកលលោក ។ រាជរដ្ឋាភិបាលបានកសាងគោលនយោ-បាយការកែលម្អច្បាប់ និងការពង្រឹងការអនុវត្ត ព្រមទាំងការកសាងសមត្ថភាព បុរសស្ត្រី និងយុវវ័យឱ្យដល់កម្រិតខ្ពស់មានជាអាទិ៍ ការសិក្សាផ្នែកវិទ្យាសាស្ត្រ ការធ្វើឯកទេសកម្មជំនាញបច្ចេកទេសវិជ្ជាជីវៈ កម្រិតខ្ពស់ ការធ្វើសុក្រឹត្យការ វិក្រឹត្យការ ជំនាញបច្ចេកវិទ្យាព័ត៌មាន និងភាសាបរទេស ព្រមទាំងការអប់រំក្រៅផ្លូវការរួមមានសីលធម៌និងគុណធម៌ផងដែរ ដើម្បីរួមចំណែកឈានទៅសម្រេចបានចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលនឹងប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍ នៅឆ្នាំ២០៥០។

ការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច បានធ្វើឱ្យកំណើនសេដ្ឋកិច្ចកម្ពុជាមានកំណើនខ្ពស់ប្រហែល




**លោកជំទាវរដ្ឋមន្ត្រី ជូនកន្ត្រកផ្កា និងវត្ថុអនុស្សាវរីយ៍ លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច**

៧.២%ក្នុង១ឆ្នាំ ដែលបានមកពីវិស័យនាំមុខ រួមមានទេសចរណ៍ កសិកម្ម ឧស្សាហកម្មកាត់ដេរនិងសំណង់ ចំណែកឯអត្រានៃភាពក្រីក្រ ត្រូវបានកាត់បន្ថយ ប្រហែល ១%ក្នុងមួយឆ្នាំ។

យុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រ និងការវិនិយោគលើវិស័យកសិកម្ម និងឧស្សាហកម្មបានរួមចំណែកលើកកម្ពស់ជីវភាពស្រ្តីតាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធដូចជាការស្ថាបនាផ្លូវជាតិ ផ្លូវលំជនបទ មណ្ឌលសុខភាពតាមឃុំ ដែលជួយឱ្យស្រ្តីស្វែងរកសេវាសុខភាពកាន់តែប្រសើរ និងទាន់ពេលវេលា និងទទួលបានការងារ និងប្រាក់ចំណូលកាន់តែច្រើនសម្រាប់ការលើកកម្ពស់ ជីវភាពរស់នៅ។

រាជរដ្ឋាភិបាលបានអនុម័តគោលនយោបាយជាតិគាំពារសង្គមសម្រាប់ ជនក្រីក្រ និងងាយរងគ្រោះនៅក្នុងឆ្នាំ២០១១។ ស្រ្តីនិងកុមារក្រីក្រ និងក្រុមជនងាយរងគ្រោះបានទទួលផលប្រយោជន៍ពីបណ្តាញសុវត្ថិភាពសង្គម។ យុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្របានលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស ផ្តល់អាហារូបត្ថម្ភពង្រឹងសុខភាពមាតានិងទារក លើកកម្ពស់ការអប់រំ និង លុបបំបាត់ពលកម្មកុមារ ជាពិសេសទម្រង់ពលកម្មធ្ងន់ធ្ងរ។

ក្នុងវិស័យអប់រំរាជរដ្ឋាភិបាលនីតិកាលទី៥កំពុងជំរុញការអនុវត្តគោលការណ៍ "**ការអប់រំសម្រាប់ទាំងអស់គ្នា** " សំដៅធានាសមធម៌ក្នុងការទទួលបានសេវាអប់រំ បន្តលើកកម្ពស់គុណភាព និងប្រសិទ្ធភាព នៃ

សេវាអប់រំគ្រប់កម្រិត ព្រមទាំងបន្តអភិវឌ្ឍស្ថាប័ន និងសមត្ថភាពមន្ត្រីអប់រំការបន្តរៀបចំការកែលម្អគោលនយោបាយ និងយុទ្ធសាស្ត្រវិស័យអប់រំ ពិសេសការធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រ វិស័យអប់រំ ផែនការបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ក្នុងវិស័យអប់រំ និងគោលនយោបាយ ស្ដីពី ការអភិវឌ្ឍជ ការស្រាវជ្រាវក្នុងវិស័យអប់រំ ដើម្បីកសាង និងអភិវឌ្ឍធនធានមនុស្ស ប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌ក្នុងគ្រប់វិស័យសំដៅឆ្លើយតបទៅនឹងសេចក្ដីត្រូវការនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ច និងពង្រឹងការប្រគួតប្រជែងរបស់កម្ពុជាក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ។ គោលនយោបាយ និងកម្មវិធីទាំងនេះ បានធ្វើឱ្យសមាមាត្រសិស្សទទួលបានអាហារូបករណ៍ទៅសិក្សានៅបរទេស និងចំនួននិស្សិតជាស្ត្រីមានការកើនឡើង។ ជាក់ស្ដែងចំនួននិស្សិត ទទួលបានអាហារូបករណ៍ទៅសិក្សានៅបរទេសក្នុងឆ្នាំសិក្សា២០១២-២០១៣ មានចំនួន ២៨.៣៩៨ នាក់ ក្នុងនោះមាននិស្សិតស្រី ៣៦.៤៦% ហើយក្នុង ឆ្នាំសិក្សា២០១៣-២០១៤ មាននិស្សិតចំនួន ២៨.៦៧៦នាក់ ក្នុងនោះមាន និស្សិតស្រី ៤៤.៥%។ បើប្រៀបធៀបនឹងឆ្នាំសិក្សាកន្លងមក ចំនួននិស្សិត ថយចុះ ១% តែនិស្សិតស្រីកើនឡើង ដល់១៥.៣%។

ក្នុងការលើកកម្ពស់សមភាពយេនឌ័រ រាជរដ្ឋាភិបាល កំពុងបន្តលើកទឹកចិត្តបន្ថែមទៀត ដល់ការអភិវឌ្ឍសមត្ថភាពរបស់ស្ត្រីជាថ្នាក់ដឹកនាំ សំដៅធ្វើយ៉ាងណាឱ្យស្ត្រីបានចូលរួមកាន់តែច្រើនឡើងនៅក្នុងការធ្វើសេចក្ដីសម្រេច ទាំងក្នុងក្របខ័ណ្ឌនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ។ បច្ចុប្បន្ននេះ យើងមានស្ត្រីជាថ្នាក់ដឹកនាំនៅគ្រប់កម្រិតដែលជាមោទនភាពរបស់ស្ត្រីកម្ពុជា។

ក្រុមការងារបញ្ជ្រាបយេនឌ័រនៅតាមក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់នៅថ្នាក់ជាតិ និងនៅថ្នាក់រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវបានបង្កើតឡើង និងមានយន្តការនៅគ្រប់កម្រិតសម្រាប់ជួយដោះស្រាយនូវបញ្ហាទាំងឡាយរបស់ស្ត្រី។

គោលនយោបាយជាតិជាច្រើនបានបញ្ចូលវិធានការណ៍ដើម្បីផ្ដល់សិទ្ធិជូនស្ត្រីក្រុមងាយរងគ្រោះដែលទទួលរងអំពើហិង្សា ដូចដែលបានឆ្លុះបញ្ចាំង នៅក្នុងផែនការសកម្មភាពជាតិស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៤-២០១៨) និងផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ នារីរតនៈទី៤។

ក្នុងការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ រាជរដ្ឋាភិបាលបន្តជំរុញ អនុវត្ត និងធ្វើបច្ចុប្បន្នភាព "**ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ២០០៨-២០១៥**" ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព នៃវិស័យសុខាភិបាល សំដៅលើកស្ទួយអនាម័យ សុខភាព សុខុមាលភាព និងអាហារូបត្ថម្ភរបស់ប្រជាជនកម្ពុជា ឱ្យកាន់តែល្អប្រសើរឡើង ពិសេសសម្រាប់ប្រជាជនក្រីក្រ ជនងាយរងគ្រោះស្ត្រី និងកុមារ។

ផែនការយុទ្ធសាស្ត្រនេះរួមចំណែកធ្វើឱ្យស្ថានភាពសុខភាពមាតាមានភាពវិជ្ជមានច្រើន ដោយមានការថយចុះនូវអត្រាមរណភាពរបស់មាតាពី៤៧២/១០០.០០០ កំណើតរស់នៅឆ្នាំ ២០០៥ មក នៅត្រឹម ១៧០/១០០.០០០ កំណើតរស់នៅឆ្នាំ២០១៤ និងអត្រាស្លាប់របស់កុមារក្រោមអាយុ៥ឆ្នាំ ថយចុះជាលំដាប់គឺ១២៤នាក់/១.០០០កំណើតរស់ នៅឆ្នាំ២០០០ និងថយចុះមក៥៤នាក់ ក្នុងឆ្នាំ២០១០ ដែលគោលដៅ អភិវឌ្ឍន៍សហស្សវត្សរ៍ កំណត់ត្រឹម៦៥នាក់/១.០០០កំណើតរស់ ក្នុងឆ្នាំ២០១៥។

ថ្វីត្បិតតែវិស័យកិច្ចការនារី មានការរីកចម្រើនយ៉ាងឆាប់រហ័សក្តី ក៏ប៉ុន្តែ ស្ត្រី និងកុមារី នៅប្រទេសយើង នៅជួបប្រទះបញ្ហាប្រឈមមួយចំនួននៅឡើយ ដូចជាការរំលោភបំពានផ្លូវភេទ អំពើហិង្សា ការជួញដូរផ្លូវភេទ ការល្បួងបោកបញ្ឆោត ការរើសអើង ភាពក្រីក្រ និងសុខភាពទន់ខ្សោយ ជាដើម។ លើសពីនេះ វិសមភាពយេនឌ័រនៅមាននៅឡើយក្នុងវិស័យអប់រំ ជាពិសេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ និង ឧត្តមសិក្សាដែលអាចប៉ះពាល់ដល់កាលានុវត្តភាព ផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីមានជាអាទិ៍ការទទួលបាននូវចំណេះដឹងជំនាញនិងបច្ចេកវិទ្យាថ្មី។ បញ្ហាសុខភាពស្ត្រី អាហារូបត្ថម្ភនិងអត្រាមរណភាពរបស់ម្តាយនៅតែជាបញ្ហាប្រឈមដ៏សំខាន់នៅឡើយ បើប្រៀបធៀបទៅនឹងប្រទេសដទៃនៅក្នុងតំបន់។ ការដោះស្រាយបញ្ហាអំពើហិង្សាលើស្ត្រី និងកុមារី ទៅតាមនីតិវិធីតុលាការនិងផ្លូវច្បាប់ នៅពុំទាន់បានរលូន និងទាន់ពេលវេលា។ ស្ត្រីចូលរួមក្នុងការធ្វើសេចក្តីសម្រេច និងនៅក្នុងវិស័យសេដ្ឋ-កិច្ចនៅមានកម្រិតនៅឡើយ ដោយសារបទដ្ឋានសង្គម និងវប្បធម៌ដែលកំណត់ឱ្យក្មេងស្រី និងស្ត្រី មិនចាំបាច់រៀនសូត្រខ្ពស់ ត្រូវនៅធ្វើការងារផ្ទះ ដែលជាហេតុធ្វើឱ្យស្ត្រីភាគច្រើនធ្វើការងារមានប្រាក់កម្រៃទាបងាយរងគ្រោះ និងការចូលរួមក្នុងវិស័យសាធារណៈ និងនយោបាយ នៅមានកម្រិត។

ការប្រឈមទាំងនេះ គឺដោយសារមូលហេតុមួយចំនួន ដូចជា៖ កង្វះធនធាន កង្វះការយល់ដឹងពីតម្លៃរបស់ស្ត្រី ការរើសអើងរបស់មនុស្សខ្លះក្នុងសង្គម ការភ្លើតភ្លើនទៅតាមសម្ភារៈអូសទាញ ការវិវឌ្ឍផ្នែកសេដ្ឋកិច្ច និងសង្គមនៅលើពិភពលោក និងនៅកម្ពុជា ការកើនឡើងនៃទេសន្តប្រវេសន៍ឆ្លងដែន ការកើនឡើងនៃសេវាកម្មទេសចរណ៍ជាពិសេសក្នុងវិស័យកម្សាន្ត ការប្រើខុសទិសដៅ នៃបច្ចេកវិទ្យាទំនើប ដូចជាទូរស័ព្ទ អ៊ីនធឺណិត និងបណ្តាញសង្គម ដូចជា ហ្វេសប៊ុក ជាដើម ដែលអាចឱ្យប៉ះពាល់ទៅលើសេចក្តីថ្លៃថ្នូរ កិត្តិយស និងតម្លៃរបស់ស្ត្រីខ្មែរ ក្នុងគ្រួសារ ក្នុងសង្គមនិងប្រទេសជាតិ។

ការប្រឈមខាងលើនេះ តម្រូវឱ្យយើងរួមគ្នាប្រឹងប្រែងចាត់វិធានការរកដំណោះស្រាយ ឱ្យបានទាន់ពេលវេលា តាមគ្រប់រូបភាព។

*សមាជិកាសមាជិកនៃអង្គសន្និបាតទាំងអស់ជាទីរាប់អាន!*

ដើម្បីរួមចំណែកធ្វើឱ្យសម្រេចបានជោគជ័យនៃការអនុវត្តផែនការនារីរតនៈទី៤ និងបណ្ដាសកម្មភាព ដែលលើកឡើងនៅក្នុងអង្គសន្និបាតនេះ ព្រមទាំងជាជំនួយដល់ការលើកទិសដៅការងារឆ្នាំ២០១៥នេះ ខ្ញុំសូមផ្ដល់ជាមតិនិងអនុសាសន៍មួយចំនួនជូនដល់អង្គសន្និបាតដូចតទៅៈ

***ទី១***- *ថ្នាក់ដឹកនាំមន្ត្រីគ្រប់លំដាប់ថ្នាក់របស់ក្រសួងកិច្ចការនារី អភិបាល រងខេត្តដែលទទួលបន្ទុកកិច្ចការនារីគណៈកម្មការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុមប្រឹក្សារាជធានីខេត្តស្រុកខណ្ឌព្រមទាំងក្រុមការងារបញ្ជ្រាបយេនឌ័រនៅតាមក្រសួងនានា ត្រូវបន្តសហការគ្នាឱ្យបានល្អក្នុងការកសាងបណ្ដាញស្ត្រីជាអ្នកធ្វើសេចក្ដីសម្រេចនៅគ្រប់លំដាប់ថ្នាក់ ដើម្បីស្ត្រីមានសិទ្ធិពេញលេញក្នុងការដឹកនាំ គ្រប់គ្រង និងកសាងសេដ្ឋកិច្ចគ្រួសារ ចៀសផុតពីការរំលោភ បំពានអំពើហិង្សាព្រមទាំងទទួលបាននូវការគោរពនិងផ្ដល់កិត្តិយស និងតម្លៃពីសមាជិកគ្រួសារនិងសង្គម។*

***ទី២***-*គ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវបន្តកិច្ចសហការឱ្យកាន់តែខ្លាំងក្លាថែម ទៀតលើការពង្រឹងការអនុវត្តច្បាប់ និងគោលនយោបាយផ្សេងៗបង្កើនការបញ្ជ្រាបយេនឌ័រទៅក្នុងផែនការគ្រប់វិស័យនិង ផែនការអភិវឌ្ឍថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។*

***ទី៣***-*គ្រប់ស្ថាប័នពាក់ព័ន្ធត្រូវបង្កើនយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈ អំពីច្បាប់ គោលនយោបាយពាក់ព័ន្ធកិច្ចការពារសិទ្ធិ និងផលប្រយោជន៍ស្ត្រី ដើម្បីបង្កើនការគាំទ្រនិងចូលរួមចំណែកពីសហគមន៍ក្នុងការធ្វើសេចក្ដីសម្រេច សិទ្ធិស្មើភាពលើគ្រប់វិស័យរវាងស្ត្រី និងបុរស កាត់បន្ថយជាអតិបរមានូវអំពើហិង្សាក្នុងគ្រួសារ ការបោកបញ្ឆោត ល្បួងលួងលោម និងអំពើរំលោភសេពសន្ថវៈ។*

***ទី៤***-*ក្រសួងកិច្ចការនារីត្រូវបន្តធ្វើការបណ្ដុះបណ្ដាល និងកសាង សមត្ថភាពធនធានមនុស្ស ព្រមជាមួយការលើកកម្ពស់ប្រសិទ្ធភាព នៃការអនុវត្តការងាររបស់អង្គភាពគ្រប់លំដាប់ថ្នាក់នៅក្រោមឱវាទរបស់ខ្លួន ដើម្បីធានាសម្រេចបាននូវភារកិច្ច សម្រាប់ជាឧត្ដមប្រយោជន៍ជាតិនិងប្រជាពលរដ្ឋកម្ពុជា។*

***ទី៥***-*មន្ត្រី និងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់របស់ក្រសួងកិច្ចការនារី ត្រូវយកលទ្ធផលបានមកពីកិច្ចពិភាក្សារបស់សន្និបាតនាពេលនេះ ធ្វើជាផែនទីបង្ហាញផ្លូវសម្រាប់អនុវត្តទិសដៅការងារឆ្នាំ២០១៥ របស់ក្រសួងកិច្ចការនារីឱ្យបានជោគជ័យ៕*

*******




**ឯកឧត្តម ហ៊ុន ម៉ានី សមាជិកសភាវ័យក្មេង ជាគណៈអធិបតីក្នុងអង្គពិធី**

ក្រសួងកិច្ចការនារី សហការជាមួយអង្គការ UNFPA និងសមាគមអភិវឌ្ឍសុខភាពប្រជាជន បានរៀបចំវេទិកាយុវជនជជែកពិភាក្សា ស្ដីពី យេនឌ័រ និងការចូលរួមរបស់យុវជនជាបុរសដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី ក្នុងយុទ្ធនាការ "**បុរសល្អ**" ថ្នាក់ជាតិ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ នៅស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា។

វេទិកាពិភាក្សានេះមានការប្រកួតជជែងពិភាក្សាចំនួន៣វគ្គ រវាងនិស្សិតចំនួន១៥រូប មកពីសាលាចំនួន ៤ គឺ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាលាជាតិកសិកម្មព្រែកលៀប សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

នាឱកាសនោះ លោកជំទាវរដ្ឋមន្ត្រីបានមានប្រសាសន៍ថា វេទិកាយុវជនជជែកពិភាក្សា ស្ដីពី យេនឌ័រ គឺជាសកម្មភាពប្រកបដោយភាពឆ្នៃប្រឌិត ក្នុងការគៀងគរក្រុមបុរសវ័យក្មេងឱ្យបានចូលរួមពិភាក្សា និងធ្វើសកម្មភាព ដើម្បីរួមចំណែកទប់ស្កាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រី តាមរយៈការជម្រុញ និងលើកកម្ពស់ការចូលរួមរបស់យុវជនជាបុរស និងក្មេងប្រុសដើម្បីផ្លាស់ប្ដូរពួកគេឱ្យក្លាយទៅជាភ្នាក់ងារយ៉ាងសំខាន់ក្នុងការចូលរួមទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី ។

***សារៈសំខាន់ៗទាំង៦នៃយុទ្ធនាការបុរសល្អរួមមានៈ***





***១. ខ្ញុំចូលរួមបញ្ឈប់អំពើហិង្សាលើស្ត្រី***

***២. ខ្ញុំចែករំលែកកិច្ចការផ្ទះ***

***៣. ខ្ញុំដោះស្រាយបញ្ហាដោយការពិភាក្សាគ្នា***

***៤. ខ្ញុំធ្វើខ្លួនជាគំរូល្អក្នុងការលើកកម្ពស់សមភាព រវាងបុរស និងស្ត្រី***

***៥. ខ្ញុំធ្វើការសម្រេចចិត្តរួមគ្នា និង***

***៦.ខ្ញុំយកចិត្តទុកដាក់ចំពោះបុរស និងស្ត្រីស្មើគ្នា។***

ក្នុងឱកាសនោះដែរ ឯកឧត្តម **ហ៊ុន ម៉ានី** តំណាងរាស្ត្រ និងសមាជិកសភាវ័យក្មេង បាន លើកឡើងថា៖ យុវជនជាសក្តានុពលមិនចេះរីងស្ងួត និងជាសសរទ្រូងរបស់ប្រទេសជាតិ ក្នុងការ អភិវឌ្ឍសង្គម រួមទាំងការចូលរួមចំណែកនៅគ្រប់ កម្រិត និងទីកន្លែងលើកស្ទួយសមភាពយេនឌ័រទប់ស្កាត់ និងកាត់បន្ថយអំពើហិង្សាលើស្ត្រី។***សារ៉ាត់***



លោកជំទាវរដ្ឋមន្ត្រីជូនប័ណ្ណសរសើរដល់ក្រុមនិស្សិតដែលបានទទួលជ័យលាភី

# ស្ត្រីទណ្ឌិតមានផ្ទៃពោះ និងមានកូនតូចត្រូវបានលើកលែងទោស








**លោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារី ចែកអំណោយស្ត្រីទណ្ឌិតមានកូនតូច**

កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ក្នុងសន្និបាតបូកសរុបការងារប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី បានស្នើសុំឱ្យក្រសួងកិច្ចការនារីសហការជាមួយក្រសួងយុត្តិធម៌ពិនិត្យលើការដោះលែងស្ត្រីទណ្ឌិតដែលមានកូនតូច និងមានផ្ទៃពោះ។ ការដោះលែងទោសដល់ស្ត្រីមានចំនួន២លើក៖ អនុវត្តន៍តាមព្រះរាជក្រិត្យលើកលែងទោសតាមសំណើនាយករដ្ឋមន្ត្រី។

-លើកទី១ ធ្វើនៅថ្ងៃទី៨ ក្នុងខែមីនា ឆ្នាំ២០១៥ មានទណ្ឌិតជាស្ត្រីចំនួន២២នាក់ (ស្ត្រីមានគភ៌ ១នាក់ និងស្ត្រីមានកូនតូច២១ នាក់)។

-លើកទី២ ធ្វើនៅព្រឹកថ្ងៃអាទិត្យ ទី១២ ខែមេសា ឆ្នាំ២០១៥ នៅពន្ធនាគារព្រៃស ម២ ដែលមានលោកជំទាវវេជ្ជ. **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារីចូលរួម។ ស្ត្រីដែលត្រូវដោះលែងទោសមានចំនួន ៣៧នាក់ (ស្ត្រីមានគភ៌ ១៤នាក់ និងស្ត្រីមានកូនតូច២៣ នាក់)។ សរុបស្ត្រីទណ្ឌិតដែលបានទទួលការលើកលែងទោសមានចំនួន ៥៩នាក់៕ ***យិន សារ៉ាត់***

# អ្នកគ្រូកម្ពុជាទីមួយ ត្រូវបានជ្រើសតាំង ជាឯកអគ្គរដ្ឋទូត សុច្ឆន្ទៈសម្រាប់ការអប់រំពិភពលោក




សម្តេចតេជោបំពាក់គ្រឿងឥស្សរិយយសជូនអ្នកគ្រូ នាងផល្លា

អ្នកគ្រូ **នាង ផល្លា** ជាបេក្ខនារីមួយរូបក្នុងចំណោមបេក្ខជនគ្រូបង្រៀនឆ្នើមសរុបជាង ៥.០០០នាក់ មកពី១២៧ប្រទេស។ អ្នកគ្រូត្រូវបានជ្រើសរើសជាប់ក្នុងបញ្ជីគ្រូបង្រៀនឆ្នើមពិភពលោក ១០នាក់ចុងក្រោយដែលនឹងប្រកួតគ្នា ដោយអ្នកឈ្នះនឹងទទួលពានរង្វាន់ជាមួយទឹកប្រាក់១លានដុល្លារសហរដ្ឋអាមេរិក ពីកម្មវិធីពានរង្វាន់គ្រូឆ្នើមពិភព លោក " Global Teacher Prize " នៃមូលនិធិ VAR KEY Foundation នៅក្នុងទីក្រុងឌូបៃ នៃប្រទេសអេមីរ៉ាត អារ៉ាប់រួម កាលពីថ្ងៃទី ១៥ខែ មីនា ឆ្នាំ២០១៥។

អ្នកគ្រូ **នាង ផល្លា** ជានាយិកាសាលាកុមារពិការភ្នែក និងកុមារគថ្លង់នៃអង្គការគ្រួសារថ្មីដែលមានទីតាំងនៅសង្កាត់ឃ្មួញខណ្ឌសែនសុខ រាជធានីភ្នំពេញ។

អ្នកគ្រូ **នាង ផល្លា** បានថ្លែងថាៈ"ខ្ញុំមិនបានឈ្នះពានរង្វាន់ប្រាក់មួយលានដុល្លារពីកម្មវិធី Global Teacher Prize នោះទេប៉ុន្តែខ្ញុំត្រូវបានគណៈកម្មការរៀបចំកម្មវិធីនេះ **ជ្រើសតាំងជាឯកអគ្គរដ្ឋទូតសុច្ឆន្ទៈ** សម្រាប់ការអប់រំពិភពលោក និងផ្តល់




**អ្នកគ្រូ នាង ផល្លា ថតរូបជាមួយលោកប៊ីលគ្លីនតុន**

មេដាយមាសមួយ ប័ណ្ណសរសើរមួយ ព្រមទាំងប្រាក់រង្វាន់លើកទឹកចិត្តចំនួន ២៥,០០០ដុល្លារ **អាមេរិក។**

**ស្ថិតក្នុងទឹកមុខញញឹមបង្កប់ដោយភាពម៉ឺងម៉ាត់** អ្នកគ្រូ **នាង ផល្លា** បានប្រាប់អ្នកយកព័ត៌មាននារីរតនៈយើងថាៈ ខ្ញុំមានកិត្តិយសខ្លាំងមែនទែន ដែលបានជាប់ជាបេក្ខជនក្នុងចំណោមគ្រូឆ្នើម ពិភពលោក១០នាក់ចុងក្រោយ។ ពេលដាក់ពាក្យប្រលង ខ្ញុំមានគោលបំណងសំខាន់ៗពីរ គឺទីមួយចង់លើកស្ទួយវិស័យអប់រំក្នុងប្រទេសកម្ពុជា ព្រោះថាយើងមានការអប់រំដល់សិស្សពិការភ្នែក និងសិស្សគថ្លង់ក្នុងប្រទេសកម្ពុជាក៏មិនអន់ជាង ប្រទេសគេដែរ ទីពីរ គឺដើម្បីរកថវិកាទ្រទ្រង់ដំណើរ ការនៅក្នុងអង្គការ។

អ្នកគ្រូ **នាង ផល្លា** បន្តថា ពេលដែលបានជាប់នៅក្នុងចំណោម១០នាក់នោះ គឺជាមោទនភាពរបស់អ្នកគ្រូ លោកគ្រូ បង្រៀនសិស្សពិការភ្នែក និងគថ្លង់ក្នុងអង្គការគ្រួសារថ្មីទាំងអស់ និងក៏ដូចជារបស់គ្រូបង្រៀនទាំងអស់នៅក្នុងប្រទេសកម្ពុជាផងដែរ។ ម្យ៉ាងវិញទៀតខ្ញុំមហាសែនរំភើបដែលបានពិភពលោកទទួលស្គាល់នូវការងាររបស់ខ្ញុំ និងការងាររបស់អង្គការគ្រួសារថ្មី មានទាំងប្រជាជនខ្មែរក្រៅប្រទេស និងក្នុងប្រទេស ជាពិសេសមានការគាំទ្រពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងពីសំណាក់អ្នកឧកញ៉ា ឯកឧត្តមលោកជំទាវ ដែលបានទទួលស្គាល់ និងអបអរនូវស្នាដៃការងាររបស់នាងខ្ញុំ ដែលបានផ្តល់ការអប់រំដល់កុមារពិការភ្នែក និង គ ថ្លង់ អស់រយៈពេលជាច្រើនឆ្នាំកន្លងមក ។

កាលពីឆ្នាំ១៩៨៦ អ្នកគ្រូ **នាង ផល្លា** ធ្វើការ និងបង្រៀនកុមារពិការភ្នែក គ ថ្លង់ និងពិការគ្រប់ប្រភេទ ហើយជានាយកសាលាអង្គការសហប្រជាជាតិក្នុងជំរំជនភៀសខ្លួនប្រទេសថៃ។ អ្នកគ្រូបានត្រឡប់មកប្រទេសកម្ពុជាវិញនៅឆ្នាំ១៩៩១ និងធ្វើការឱ្យអង្គការគ្រួសារថ្មីតាំងពីឆ្នាំ១៩៩៣ ជាគ្រូបង្រៀនកុមារពិការភ្នែកដំបូងគេក្នុងប្រទេសកម្ពុជា។

អ្នកគ្រូ **នាង ផល្លា** បានលើកឡើងថា ដោយការខិតខំប្រឹងប្រែងធ្វើឱ្យអង្គការរបស់អ្នកគ្រូអាចពង្រីកសាលាពិការភ្នែកនៅខេត្តបាត់ដំបង សៀម-រាប និងកំពង់ចាម។ កាលពីដើមឆ្នាំ១៩៩៣ ក្នុងសាលាគ្រួសារថ្មីមានសិស្សតែ៨នាក់គត់ ក្រោយមក

សាលាទទួលបានសិស្សកើនឡើងដល់ទៅជាង ៣០នាក់។ បច្ចុប្បន្ននេះមានសិស្សមួយចំនួនបានក្លាយជាគ្រូបង្រៀននៅសាលាគ្រួសារថ្មី ដូចជាគ្រូផ្នែក Computer គ្រូភាសាអង់គ្លេស ជាដើម។ ថ្មីៗនេះ យើងមានសិស្សពិការមួយចំនួនដែលគាត់រៀនចប់ ហើយប្រលងបានអាហារូបករណ៍នៅសកលវិទ្យាល័យបញ្ញាសាស្ត្រផ្នែកភាសាអង់គ្លេស គាត់ បានទទួលសញ្ញាប័ត្រ ហើយបានប្រលងជាប់ចូលធ្វើការនៅក្រសួងការបរទេស និងមួយចំនួនទៀតធ្វើការនៅទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសង្គមកិច្ច។

អ្នកគ្រូ **នាង ផល្លា** បានមានប្រសាសន៍បន្តថាខ្ញុំជាស្ត្រីមួយរូប តែមិនភ្លេចទេចំពោះការងារផ្ទះដែលត្រូវធ្វើជាប្រចាំ ព្រោះយើងជាកូនខ្មែរ។ ហើយកត្តាដែលធ្វើឱ្យយើងទទួលបានជោគជ័យ គឺដោយសារមានការគាំទ្រពីស្វាមី ពីក្រុមគ្រួសារតែម្តងដែលចេះយោគយល់ជួយគ្នាទៅវិញទៅមក និងជួយជម្រុញលើកទឹកចិត្ត ដើម្បីឱ្យយើងសម្រេចបាននូវគោលបំណង។

អ្នកគ្រូ**នាង ផល្លា**ជួបបញ្ហាប្រឈមមួយចំនួនដូចជាពេលចាប់ផ្តើមអនុវត្តការងារដំបូងមានការលំបាកខ្លាំងមែនទែន មិនមានធនធានសម្រាប់បង្រៀនទេ ហើយពេលដែលចុះទៅរកសិស្ស និងស្រង់ស្ថិតិសិស្ស ពេលខ្លះមាតាបិតាសិស្សលាក់ព័ត៌មានកូនរបស់គាត់មិនចង់ប្រាប់ ព្រោះគាត់ខ្លាចខ្មាស់គេដោយមានកូនពិការ និងគិតថាអ្នកជិតខាងមានការរើសអើងជាមួយកូនគាត់។ បើខ្ញុំមិនជំនះរាល់ឧបសគ្គទាំងឡាយទេ គឺមិនមានថ្ងៃនេះឡើយ ខ្ញុំបានព្យាយាមដោយឆន្ទៈដើម្បីធ្វើយ៉ាងណាឱ្យការអប់រំសម្រាប់កុមារពិការទទួលបានជោគជ័យ៕

***ខេមរា***



**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងថ្នាក់ដឹកនាំ ឯកឧត្តម ហ៊ុន ម៉ានី សមាជិកសភាវ័យក្មេង ជាមួយអ្នកគ្រូ នាង ផល្លា**

# ម្ចាស់មេដាយមាសចំនួន១៦



**សម្តេចតេជោបំពាក់គ្រឿងឥស្សរិយសដល់ លោកស្រី កែ ឡេងកីឡាការិនីប៉េតង់**

លោកស្រី **កែ ឡេង** ជាកីឡាការិនីដ៏ល្បីឈ្មោះក្នុងប្រភេទកីឡាប៉េតង់ ដែលបានឈ្នះមេ-ដាយមាសក្នុងការប្រកួតកីឡាប៉េតង់ពិភពលោកច្រើនជាងគេរហូតដល់១៦គ្រឿង។

លោកស្រី **កែ ឡេង** បានទទួលគ្រឿងឥស្សរិយសថ្នាក់ជាតិមហាសេរីវឌ្ឍន៍ និងប្រាក់រង្វាន់ចំនួន៦៤លានរៀលពីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណា-ចក្រកម្ពុជា និងទទួលបានប្រាក់រង្វាន់ពីរាជរដ្ឋា-ភិបាលចំនួន៨០លានរៀល ក្រោយពីលោកស្រី **កែ ឡេង** បានទទួលជ័យជំនះក្នុងព្រឹត្តិការណ៍ Women's World Championship of Petanque កាលពីឆ្នាំ២០១៣ នៅប្រទេសបារាំង។ លោកស្រីបានចេញទៅប្រកួតប្រជែងលើឆាកអន្តរជាតិសំខាន់ៗ ដោយដណ្តើមមេដាយមាសក្នុងស៊ីហ្គេមកីឡាប៉េតង់មុនដំបូងនៅប្រទេសសាំងហ្គាពួនាឆ្នាំ ១៩៩៩ បន្ទាប់មកទទួលបានមេដាយមាស ក្នុងការប្រកួតនៅប្រទេសម៉ាឡេស៊ី ប្រទេសឡាវ ប្រទេសវៀតណាម ប្រទេសបារាំង និងចុងក្រោយបានដណ្តើមមេដាយមាសកម្រិតអាស៊ីអាគ្នេយ៍ ក្នុងការប្រកួតកីឡាស៊ីហ្គេមលើកទី២៧ នៅទីក្រុងណៃពិដោ ប្រទេសមីយ៉ាន់ម៉ា ។

ស្ថិតក្នុងទឹកមុខញញឹមបង្កប់ដោយភាពម៉ឺងម៉ាត់ លោកស្រី **កែ ឡេង** បានប្រាប់អ្នកយកព័ត៌មានយើងថា: " ខ្ញុំបានចាប់យកអាជីពកីឡាប៉េតង់តាំងឆ្នាំ១៩៩៧មកម្លេះ ហើយគន្លឹះក្នុងការទទួលបានជោគជ័យ និងដើម្បីលេងកីឡាប៉េតង់ឱ្យបានខ្លាំង គឺនៅពេលដែលយើងប្រកួត ត្រូវតែដឹង






ពីបច្ចេកទេសរបស់ដៃគូ និងបូកផ្សំទាំងមានឆន្ទៈរបស់ខ្លួនឱ្យច្បាស់លាស់ ពិសេសត្រូវសង្កេតមើលឱ្យបានច្បាស់ពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ដៃគូប្រកួត និងផ្ចង់អារម្មណ៍ឱ្យបានល្អ " ។

លោកស្រី **កែ ឡេខ** បន្តទៀតថា កត្តាដែលធ្វើឱ្យយើងបានទទួលជោគជ័យមកដល់ពេលនេះគឺ ការខិតខំប្រឹងប្រែង និងព្យាយាមអត់ធ្មត់ ពិសេសការប្តេជ្ញាចិត្ត និងការតាំងចិត្តខ្ពស់ក្នុងការហ្វឹកហាត់ ព្រោះមនុស្សម្នាក់ៗមិនថាស្រី ឬប្រុសទេ តែងតែជួបការលំបាកគ្រប់បែបយ៉ាង ប៉ុន្តែយើងមិនត្រូវចុះចាញ់ឡើយ។ យើងត្រូវជំនះនូវការលំបាក និងឧបសគ្គទាំងនោះឱ្យបាន កុំគិតថាខ្លួនយើងទន់ខ្សោយមិនរឹងមាំដូចបុរស ស្ត្រីត្រូវមានកម្លាំងចិត្ត និងមានប្រាជ្ញាអាចធ្វើអ្វីបានដូចបុរសដែរ។

កីឡាការិនី **កែ ឡេខ** កើតនៅឆ្នាំ ១៩៧០ រស់នៅភូមិក្រាំងលាវ ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ ជាកូនកំព្រាឪពុក ម្តាយ និងជាកូនស្រីពៅក្នុងចំណោមបងប្អូន៩នាក់ ប៉ុន្តែស្លាប់ជំនាន់ប៉ុលពតអស់ ៧នាក់។

លោកស្រី **កែ ឡេខ** បានរៀបអាពាហ៍ពិពាហ៍ជាមួយបុរសម្នាក់ជាមន្ត្រីកងទ័ពជើងគោក និងមានកូន២នាក់ (ស្រីមួយ) ដែលសព្វថ្ងៃកូនប្រុសអ្នកស្រីជាមន្ត្រីបម្រើការងារនៅក្រសួងការពារជាតិ និងចូលចិត្តលេងកីឡាប៉េតង់ដូចម្តាយដែរ ចំណែកកូនស្រីកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ៕

*សុខខេង*

# គំនូសបំព្រួញ នៃផែនការយុទ្ធសាស្ត្រ **នារីរតនៈទី៤** ដើម្បីសមភាពយេនឌ័រនិងការបង្កើនភាពអង់អាចដល់ស្ត្រី ឆ្នាំ២០១៤ - ២០១៨

| | | |
|---|---|---|
| **១. កំណើនសេដ្ឋកិច្ច**<br>១.១. ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី | **២. លទ្ធភាពទទួលបានសេវាសង្គម និងកិច្ចគាំពារសង្គម**<br>២. ១. ការអប់រំស្ត្រី និងក្មេងស្រី និងការផ្លាស់ប្តូរឥរិយាបថ<br>២. ២. ការលើកកម្ពស់សុខភាព អាហារូបត្ថម្ភសម្រាប់ស្ត្រីនិងកុមារី និងទប់ស្កាត់មេរោគអេដស៍និងជំងឺអេដស៍<br>២. ៣. កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងកុមារី | **៣. បញ្ហាអន្តរវិស័យ**<br>៣.១. ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេច និងការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល<br>៣. ២. យេនឌ័រ និងបម្រែបម្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ |

**៤. ការអភិវឌ្ឍស្ថាប័ន និងសមត្ថភាពសម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ**